ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# ឯកសារគោល

# ការងាររៀបចំទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧

# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# នៅសាលមហោស្រពកោះពេជ្រ

Base Document on Preparing
National Anti-human Trafficking day
December 12, 2017 at Koh Pich Theater

**រៀបចំដោយ**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ
ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# មាតិកា

| ល.រ | ខ្លឹមសារ |
| --- | --- |
| ១ | ព្រាងលិខិតស្នើសុំគោលការណ៍ទៅសម្តេចតេជោ ដើម្បីរៀបចំទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧ |
| ២ | រៀបចំពង្រាងលិខិតសុំគោលការណ៍ដើម្បីរៀបចំទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧ |
| ៣ | រៀបចំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ដើម្បីបង្កើតអនុគណៈកម្មការ រៀបចំកម្មវិធីនេះ |
| ៤ | ធ្វើពង្រាងសេចក្តីបង្កើត គណៈកម្មការកណ្តាលដាក់ជូនថ្នាក់ដឹកនាំ ធ្វើការសម្រេច ឯកភាពលើលិខិតស្នើសុំ |
| ៥ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំកិច្ចប្រជុំបង្កើតអនុគណៈកម្មការ ជាជំនួយក្នុងការរៀបចំទិវាជាតិ១២ធ្នូ |
| ៦ | កំណត់សមាសភាពពីគ្រប់ក្រសួង ស្ថាប័ន អង្គការ សមាគម កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ។ល។ |
| ៧ | ពង្រាងលិខិតពាក់ព័ន្ធ មតិស្វាគមន៍ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងសុន្ទរថា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ |
| ៨ | ស្នើសុំសាលមហោស្រព ដើម្បីដឹងអំពីចំនួនអ្នកចូលរួម |
| ៩ | ធ្វើការទំនាក់ទំនងទៅគ្រប់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីកំណត់សមាសភាព និងចំនួនចូលរួមជាក់លាក់ |
| ១០ | រៀបចំធ្វើលិខិតអញ្ជើញ និងផ្ញើឲ្យគ្រប់ក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធ ដែលត្រូវចូលរួម |
| ១១ | ពង្រាងពាក្យស្លោក នៃទិវាជាតិ១២ធ្នូ (បដា បាឡុង និងប៉េងប៉ោង) |
| ១២ | រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារទូរទស្សន៍ Bayon TV និង PNN ដើម្បីរៀបចំការចាក់ផ្សាយ និងផលិតខ្សែវីដេអូខ្លី ពាក់ព័ន្ធការធ្វើចំណាកស្រុកខុសច្បាប់ និងអំពើជួញដូរមនុស្ស |
| ១៣ | ប្រជុំពិភាក្សាជាមួយតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើខ្លឹមសារ អត្ថន័យ នៃការសម្តែងរបស់ក្រុមសិល្បៈនៅលើឆាក |
| ១៤ | កំណត់ចំនួនអ្នកចូលរួម ដើម្បីធ្វើការបោះពុម្ព អាឃីត សម្រាប់ពាក់ក្នុងទិវាជាតិ១២ធ្នូ |
| ១៥ | បូកសរុប វាយតម្លៃលើសមិទ្ធិផល នៃការងាររៀបចំទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១៥៨/១៧

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែ១០ ឆ្នាំ២០១៧

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ដើម្បីរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ *នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ* និងសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា: គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧ ដែលជាឆ្នាំទី១១ សម្រាប់ **ព្រះរាជាណាចក្រកម្ពុជា**។ កម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្សឆ្នាំនេះ នឹងប្រារព្ធធ្វើ *នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ* ដែលមានអ្នកចូលរួមពីគ្រប់ក្រសួង-ស្ថាប័នក្នុងរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ប្រមាណ ៣០០០នាក់ ដើម្បីជាយុទ្ធនាការរួមគ្នាបង្កើតនូវប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់អោយកាន់តែរឹងមាំ សម្រាប់ការពារប្រជាពលរដ្ឋអោយរួចផុតពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏មានសក្តានុពលក្នុងការពង្រឹង និងពង្រីកខឿនសេដ្ឋកិច្ចដ៏ល្អប្រសើរ ដើម្បីបោះជំហានទៅមុខ ឆ្ពោះទៅកាន់ចក្ខុវិស័យរួមគឺ "**កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ**"។

ដើម្បីអោយទិវាជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៧ នេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសអធិកអធម និងរឹតតែមានអត្ថន័យជ្រាលជ្រៅ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) សូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាផ្តល់កិត្តិយសអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសារដានយោបាយដ៏មានសារៈសំខាន់ជូនជនរួមជាតិ និងដើម្បីតម្រង់ទិសឲ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បន្តដឹកនាំការអនុវត្តសកម្មភាពឲ្យរឹតតែមានប្រសិទ្ធភាពខ្ពស់។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

17-10-17

សម្តេចក្រឡាហោម ស ខេង

(1)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ៤២៨/១៧ គ.ជ.ប.ជ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការ រៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០១៧

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ លើលិខិតលេខ ១៥៨/១៧ សណ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមការចាំបាច់របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ ១ ៖** ត្រូវបានបង្កើតគណៈកម្មការកណ្តាល ដើម្បីដឹកនាំរៀបចំ ត្រួតពិនិត្យ និងសម្រេច លើការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | ប្រធាន |
| ២-លោកជំទាវ **ស៊ើង សរសុចិត្តា** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣-លោកជំទាវ **សាន្ត អរុណា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤-លោកជំទាវ **គឹម សេដ្ឋានី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥-លោកជំទាវ **ខៀវ ប៊ុរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ៦-លោកជំទាវ **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិកា |
| ៧-ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-លោកជំទាវ **តាន់ វួចឆេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិកា |

៩-លោកជំទាវ កែវ ចរិយា អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកា
១០-លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិកា
១១-ឯកឧត្តម ឆ្វ រ៉ាស៊ី អនុរដ្ឋលេខាធិការក្រសួងយុត្តធម៌ សមាជិក
១២-ឯកឧត្តម ស៊ា កុសល អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅខ សំអាត អគ្គលេខាធិការ គ.ជ.ប.ជ សមាជិក
១៤-ឯកឧត្តម នាយឧត្តមសេនីយ៍ ទូច ណារ៉ុថ អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស សមាជិក
១៥-លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ សមាជិកា
១៦-លោកស្រី វរសេនីយ៍ឯក ហ៊ាន ឆវី មេបញ្ជាការរងនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិកា
១៧-លោកជំទាវ កែវ សុខពិសី អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិកា
១៨-លោក គីម សុធារិទ្ធ អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២៖** ត្រូវបានបង្កើតអនុគណៈកម្មការចំនួន ០៤ ដើម្បីជួយការងារគណៈកម្មការកណ្តាល លើការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោមៈ

**ក. អនុគណៈកម្មការខ្លឹមសារ និងផ្សព្វផ្សាយព័ត៌មាន មានសមាសភាព និងភារកិច្ចដូចខាងក្រោមៈ**

១-លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ប្រធាន
២-លោកជំទាវ ច័ន្ទ ធី រដ្ឋលេខាធិការក្រសួងព័ត៌មាន អនុប្រធាន
៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅខ សំអាត អគ្គលេខាធិការ គ.ជ.ប.ជ អនុប្រធាន
៤-លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា សមាជិកា
៥-ឯកឧត្តម ស៊ា កុសល អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៦-លោកជំទាវ សរ គីមលី អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិកា
៧-លោកជំទាវ កែវ សុខពិសី អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិកា
៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វីរៈ អគ្គលេខាធិការរង គ.ជ.ប.ជ សមាជិក
៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ីន រ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ សមាជិក
១០-ឯកឧត្តម ស៊ី ច័ន្ទតារា អគ្គនាយករងក្រសួងព័ត៌មាន សមាជិក
១១-លោកជំទាវ ជួប ណារ៉ាត់ អគ្គនាយករងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិកា
១២-ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ុល តិចេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ សមាជិក
១៣-លោក អ៊ឹង វណ្ណថា ប្រធាននាយកដ្ឋានកិច្ចការកុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៤-លោកស្រី ទ្រាំ សុខន ប្រធាននាយកដ្ឋាននៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិកា

១៥-លោក លី សុខា អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួង អប់រំ យុវជន និងកីឡា សមាជិក

១៦-លោក ជីន ចន អនុប្រធាននាយកដ្ឋាននៃក្រសួងកិច្ចការនារី សមាជិក

១៧-លោក គឹម សារិន អនុប្រធាននាយកដ្ឋាននៃក្រសួងព័ត៌មាន សមាជិក

១៨-លោក អ៊ុន មាន អនុប្រធាននាយកដ្ឋាននៃ គ.ជ.ប.ជ សមាជិក

១៩-តំណាងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ សមាជិក

២០-តំណាងដៃគូរជាតិ-អន្តរជាតិ សមាជិក

មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំខ្លឹមសារសុន្ទរកថា ជូនសម្តេចក្រឡាហោម
- ចងក្រងខ្លឹមសារឯកសារ របាយការណ៍សង្ខេប ពាក់ព័ន្ធនឹងទិវា ១២ធ្នូ ( បដា ហ្វ៊ុង ពាក្យស្លោក ..។ល។)
- រៀបចំខ្សែវីដេអូបទយកការណ៍ស្តីពីអំពើជួញដូរមនុស្ស
- រៀបចំខ្លឹមសារសម្រាប់អ្នកសារព័ត៌មាន
- ថតចម្លងរាល់ឯកសារជូនគណៈអធិបតី ភ្ញៀវជាតិ-អន្តរជាតិ អង្គទូតនិងសមាជិក សមាជិកា
- រៀបចំកម្មវិធីសម្រាប់ពិធីមិទ្ទិញ
- ទំនាក់ទំនងធ្វើការផ្សព្វផ្សាយតាមគ្រប់បណ្តាញផ្សព្វផ្សាយព័ត៌មាន
- ធ្វើរបាយការណ៍ជាប្រចាំជូនគណៈកម្មការកណ្តាល
- ធ្វើរបាយការណ៍សរុបសកម្មភាព និងលទ្ធផលក្នុងការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការជូនគណៈកម្មការកណ្តាលដើម្បីបូកសរុបមួយសប្តាហ៍ក្រោយពិធីបានបញ្ចប់
- អនុវត្តការងារផ្សេងៗទៀតដែលប្រធានអនុគណៈកម្មការប្រគល់ជូន
- លើកគម្រោងចំណាយអនុគណៈកម្មការរបស់ខ្លួន។

ខ. អនុគណៈកម្មការពិធីការ និងសិល្បៈ មានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

១-លោកជំទាវ សាន្ត អារុណា រដ្ឋលេខាធិការក្រសួងកិច្ចការនារី ប្រធាន

២-លោកជំទាវ ម៉ិញ ភុសនី រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធាន

៣-ឯកឧត្តម អ៊ិត សីលា អគ្គលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤-លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន

៥-លោកជំទាវ វ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន

៦-លោកជំទាវ ខា ផល្លីន ទីប្រឹក្សាក្រសួងព័ត៌មាន សមាជិកា

៧-លោកឧត្តមសេនីយ៍ទោ គង់ ពុទ្ធី ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ សមាជិក

៨-លោក វរសេនីយ៍ឯក កែវ សុវណ្ណារ៉ា ប្រធានក្រុមជំនួយកិច្ចការបង្កាទប់ស្កាត់ នៃ គ.ជ.ប.ជ សមាជិក

៩-លោក ប៉ុក ម្វះគ្យ ប្រធានស្តីទីនៃនាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១០-លោក **ហ៊ុន ហាន** អនុប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១១-តំណាងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃក្រសួងមហាផ្ទៃ សមាជិក

មានតួនាទី និងភារកិច្ចដូចតទៅ៖

- ទំនាក់ទំនងការងារជាមួយផ្នែកពាក់ព័ន្ធអំពីទីកន្លែង និងសមាជិកចូលរួម
- ទំនាក់ទំនងខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង
- រៀបចំលិខិតអញ្ជើញ ភ្ញៀវជាតិ-អន្តរជាតិ អង្គទូត អង្គការដៃគូ
- ទំនាក់ទំនងភ្ញៀវជាតិ-អន្តរជាតិ ស្តីពីការចូលរួម
- រៀបចំទីកន្លែងអង្គុយសម្រាប់អ្នកចូលរួម និងទទួលភ្ញៀវ
- រៀបចំបដា និងពាក្យស្លោក
- រៀបចំខ្លឹមសារ និងការសម្តែងសិល្បៈ
- រៀបចំចងប៉េងប៉ោង និងបដាសម្រាប់បង្ហោះនៅខាងមុខសាលប្រារព្ធពិធី
- ធ្វើរបាយការណ៍ជាប្រចាំជូនគណៈកម្មការកណ្តាល
- ធ្វើរបាយការណ៍សរុបសកម្មភាព និងលទ្ធផលក្នុងការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការជូនគណៈកម្មការកណ្តាលដើម្បីបូកសរុបមួយសប្តាហ៍ក្រោយពិធីបានបញ្ចប់
- អនុវត្តការងារផ្សេងៗទៀតដែលប្រធានអនុគណៈកម្មការប្រគល់ជូន
- លើកគម្រោងចំណាយរបស់អនុគណៈកម្មការរបស់ខ្លួន។

គ. អនុគណៈកម្មការសន្តិសុខ-សណ្តាប់ធ្នាប់ សុខមាលភាព មានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

១-ឯកឧត្តម នាយឧត្តមសេនីយ៍ **ទូច ណារ៉ុថ** អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស ប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឆ្វី ម៉ានីរ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ សមាជិក

៤-លោកឧត្តមសេនីយ៍ត្រី **ខ៊ែត សុគ័ន្ធ** អនុប្រធាននាយកដ្ឋានអង្គរក្ស សមាជិក

៥-តំណាងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ សមាជិក

៦-តំណាងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សមាជិក

៧-តំណាងកងរាជអាវុធហត្ថរាជធានីភ្នំពេញ សមាជិក

មានភារកិច្ចដូចតទៅ៖

- ការពារសន្តិសុខ សណ្តាប់ធ្នាប់ទាំងក្នុងនិងក្រៅពិធី
- អនុវត្តការងារសុខាភិបាល
- អនុវត្តការងារផ្សព្វផ្សាយអប់រំ
- ធ្វើរបាយការណ៍ជាប្រចាំជូនគណៈកម្មការកណ្តាល
- ធ្វើរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលក្នុងការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការជូនគណៈកម្មការកណ្តាលដើម្បីបូកសរុបមួយសប្តាហ៍ក្រោយពិធីបានបញ្ចប់
- អនុវត្តការងារផ្សេងៗទៀតដែលប្រធានអនុគណៈកម្មការប្រគល់ជូន

- លើកគម្រោងចំណាយរបស់អនុគណៈកម្មការរបស់ខ្លួន។

ឃ. អនុគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ច័ន្ទណារ៉ុំ** | អគ្គលេខាធិការរង គ.ជ.ប.ជ | ប្រធាន |
| ២-លោក **ឆេង វណ្ណា** | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| ៣-លោកវរសេនីយ៍ឯក **នី គឹមស្រេន** | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| ៤-លោក **ឯម សុជាតិ** | នាយការិយាល័យផែនការហិរញ្ញកិច្ច និងភស្តុភារ | សមាជិក |
| ៥-លោក **អ៊ុំ វណ្ណជា** | នាយរងការិយាល័យផែនការហិរញ្ញកិច្ច និងភស្តុភារ | សមាជិក |
| ៦-កញ្ញា **អ៊ុំ ស៊ូគីម** | នាយរងការិយាល័យផែនការហិរញ្ញកិច្ច និងភស្តុភារ | សមាជិកា |

មានភារកិច្ចដូចតទៅ៖

- រៀបចំគម្រោងចំណាយថវិកាជាក់លាក់ ច្បាស់លាស់ សម្រាប់បម្រើឲ្យការប្រារព្ធទិវាជាតិ ១២ ធ្នូ ឆ្នាំ ២០១៧ និងស្នើសុំទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ពិនិត្យលើតម្រូវការថវិកាដែលស្នើដោយអនុគណៈកម្មការនីមួយៗ ដើម្បីសុំការសម្រេចពី គណៈកម្មការកណ្តាលដោយផ្អែកលើធនធាន
- ការចំណាយត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន
- រៀបចំរបាយការណ៍ទូទាត់ឲ្យបានជ្រះស្រឡះក្នុងឆ្នាំអនុវត្ត
- សម្របសម្រួលក្នុងការផ្តល់ថវិកាឲ្យបានទាន់ពេលវេលា
- ធ្វើរបាយការណ៍ជាប្រចាំជូនគណៈកម្មការកណ្តាល
- ធ្វើរបាយការណ៍សរុបសកម្មភាព និងលទ្ធផលក្នុងការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការ ជូនគណៈកម្មការកណ្តាលដើម្បីបូកសរុបមួយសប្តាហ៍ក្រោយពិធីបានបញ្ចប់។

**ប្រការ ៣ ៖** អនុគណៈកម្មការទាំង ០៤ ខាងលើមានសិទ្ធិជ្រើសរើសសមាជិក សមាជិកាបន្ថែម ដើម្បីបំពេញការងារតាមការចាំបាច់ និងចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការកណ្តាល។

**ប្រការ ៤ ៖** លោកជំទាវ ឯកឧត្តម លោក-លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ និង ប្រការ ២ និងគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់ពិធីបានបញ្ចប់។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**សម្តេចក្រឡាហោម ស ខេង**

*កន្លែងទទួល៖*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ*
- *សាលារាជធានីភ្នំពេញ*
- *ដូចប្រការ ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន
លេខៈ ១៥៧/១៧ អ.ល.ក

# លិខិតបង្គាប់ការ

## ស្តីពី

## ការចាត់តាំងក្រុមជំនួយការ ជួយការងារគណៈកម្មការកណ្តាល និងអនុគណៈកម្មការ រៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០១៧

## អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- យោងសេចក្តីសម្រេចលេខ ២១៩/១៧ សសរ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតសមាសភាពគណៈកម្មការកណ្តាល និងអនុគណៈកម្មការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០១៧ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## សម្រេច

**ប្រការ ១៖** ត្រូវបានបង្កើតក្រុមជំនួយការចំនួន ០៧ ក្រុម របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជួយការងារគណៈកម្មការកណ្តាល និងអនុគណៈកម្មការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

ក្រុមទី ០១ ៖ ក្រុមការងារទំនាក់ទំនងភ្ញៀវជាតិ និងអន្តរជាតិ

អំពីសមាសភាព៖

| | | |
|---|---|---|
| ១-លោកឧត្តមសេនីយ៍ទោ គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន | ប្រធាន |
| ២-លោកឧត្តមសេនីយ៍ត្រី ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | អនុប្រធាន |
| ៣-លោកឧត្តមសេនីយ៍ត្រី ថោង វុទ្ធី | អនុប្រធានលេខាធិការដ្ឋាន | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ត្រី កែវ ផល្លា | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៥-លោកវរសេនីយ៍ត្រី ញ៉ឹល សុផល | នាយរងការិយាល័យ | សមាជិក |
| ៦-លោកស្រីអនុសេនីយ៍ទោ ថោង សុវត្ថិ | នាយរងការិយាល័យ | សមាជិក |
| ៧-លោកវរសេនីយ៍ត្រី វ៉ា នីន | នាយផ្នែក | សមាជិក |
| ៨-លោកអនុសេនីយ៍ត្រី ចេក វណ្ណា | នាយផ្នែក | សមាជិក |
| ៩-លោកអនុសេនីយ៍ទោ ជា ពិសិដ្ឋ | មន្ត្រី | សមាជិក |

អំពីតួនាទី និងភារកិច្ច៖

- រៀបចំបញ្ជីឈ្មោះស្ថាប័ន-អង្គភាព និងចំនួនភ្ញៀវដែលត្រូវអញ្ជើញចូលរួម ។



(7)

- សហការជាមួយក្រសួង-ស្ថាប័ន និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃក្រសួងមហាផ្ទៃនិងអង្គភាពពាក់ព័ន្ធដើម្បីបំពេញការងារ
- បញ្ជូនលិខិតអញ្ជើញទៅគ្រប់អង្គភាព អង្គទូត ស្ថាប័នពាក់ព័ន្ធ រាជធានី-ខេត្ត អង្គការដៃគូ និងភ្ញៀវអញ្ជើញចូលរួម
- ទំនាក់ទំនងបញ្ជាក់ពីចំនួនវត្តមានភ្ញៀវជាតិ អន្តរជាតិចូលរួម
- អនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

ក្រុមទី ០២ ៖ ក្រុមការងារពិធីការ បដិសណ្ឋារកិច្ច និងសិល្បៈ

អំពីសមាសភាព៖

| | | |
|---|---|---|
| ១- លោកជំទាវ រ៉ែន **សិរីលក្ខណា** | អគ្គលេខាធិការរង | ប្រធាន |
| ២-លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណា សំខាន់** | អគ្គលេខាធិការរង | អនុប្រធាន |
| ៣-លោកឧត្តមសេនីយ៍ទោ គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ទោ លី តុងហ៊ុយ | ប្រធានក្រុមជំនួយកិច្ចការ | អនុប្រធាន |
| ៥-លោកឧត្តមសេនីយ៍ទោ កែប សារឿន | ប្រធានក្រុមជំនួយកិច្ចការ | អនុប្រធាន |
| ៦-លោកឧត្តមសេនីយ៍ទោ ស្រី សាមឌី | ប្រធានក្រុមជំនួយកិច្ចការ | អនុប្រធាន |
| ៧- លោកវរសេនីយ៍ឯក កែវ សុវណ្ណារ៉ា | ប្រធានក្រុមជំនួយកិច្ចការ | អនុប្រធាន |
| ៨-លោក តែ សុថាវ៉េត | ប្រធានក្រុមជំនួយកិច្ចការ | អនុប្រធាន |
| ៩-លោកឧត្តមសេនីយ៍ត្រី ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី ថោង វុទ្ធី | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១១-លោកឧត្តមសេនីយ៍ត្រី កែវ ផល្លា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២-លោកឧត្តមសេនីយ៍ត្រី ចាន់ ថារី | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៣-លោកឧត្តមសេនីយ៍ត្រី គង់ ស៊ីចន្ទ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥-លោកឧត្តមសេនីយ៍ត្រី តូច គឹមហៀក | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦-លោកឧត្តមសេនីយ៍ត្រី ខៀវ សុផល | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៧-លោកវរសេនីយ៍ឯក ស៊ុន ប៊ុណ្ណា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៨-លោកវរសេនីយ៍ឯក សិត ជាត | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៩-លោកវរសេនីយ៍ឯក សោម សិទ្ធិ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២០-លោកវរសេនីយ៍ឯក ខៀវ សំណាង | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២១-លោកវរសេនីយ៍ឯក មិន ប៊ុនរិទ្ធ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២២-លោកវរសេនីយ៍ឯក អ៊ឹម ពិសិដ្ឋ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២៣-លោកវរសេនីយ៍ឯក សេក ស៊ីវ៉េត | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២៤-លោកវរសេនីយ៍ឯក ហែម បូរ៉ា | មន្ត្រីជំនួយការ | សមាជិក |
| ២៥-លោកវរសេនីយ៍ទោ គួច ក្រិត | នាយរងការិយាល័យ | សមាជិក |
| ២៦-លោកវរសេនីយ៍ត្រី ញ៉ឹល សុផល | នាយរងការិយាល័យ | សមាជិក |
| ២៧-លោកអនុសេនីយ៍ឯក អោក ភារិន | នាយរងការិយាល័យ | សមាជិក |
| ២៨-លោកស្រីអនុសេនីយ៍ទោ ថោង សុវត្ថិ | នាយរងការិយាល័យ | សមាជិក |
| ២៩-លោកវរសេនីយ៍ត្រី រ៉ា នីន | នាយផ្នែក | សមាជិក |
| ៣០-លោកអនុសេនីយ៍ត្រី ចេក វណ្ណា | នាយផ្នែក | សមាជិក |

| | | |
|---|---|---|
| ៣១-លោកអនុសេនីយ៍ទោ ជា ពិសិដ្ឋ | មន្ត្រី | សមាជិក |
| ៣២-កញ្ញាអនុសេនីយ៍ឯក សុខ ភារ៉ា | មន្ត្រី | សមាជិក |
| ៣៣-លោកស្រីអនុសេនីយ៍ឯក គុណ តែវរស្មី | មន្ត្រី | សមាជិក |
| ៣៤-កញ្ញាអនុសេនីយ៍ត្រី អុន កណ្ណិកា | មន្ត្រី | សមាជិក |
| ៣៥-លោកអនុសេនីយ៍ត្រី ជុំ សេន | មន្ត្រី | សមាជិក |
| ៣៦-លោកស្រីអនុសេនីយ៍ត្រី ថោង សុបុទុម | មន្ត្រី | សមាជិក |
| ៣៧-លោកអនុសេនីយ៍ត្រី សួន ផៃ | មន្ត្រី | សមាជិក |
| ៣៨-លោកអនុសេនីយ៍ត្រី នន់ ឧត្តម | មន្ត្រី | សមាជិក |
| ៣៩-កញ្ញាអនុសេនីយ៍ត្រី សំ ច័ន្ទធីតា | មន្ត្រី | សមាជិក |
| ៤០-លោកអនុសេនីយ៍ត្រី ឆន ដារ៉ាវិទ្ធិ | មន្ត្រី | សមាជិក |
| ៤១-លោកអនុសេនីយ៍ត្រី ហុក ដារី | មន្ត្រី | សមាជិក |
| ៤២-លោកអនុសេនីយ៍ត្រី សេង សុភ័ក្ត្រ | មន្ត្រី | សមាជិក |
| ៤៣-កញ្ញាអនុសេនីយ៍ត្រី គឹម សុម៉ាលីន | មន្ត្រី | សមាជិក |
| ៤៤-លោកអនុសេនីយ៍ត្រី យុន សុខា | មន្ត្រី | សមាជិក |
| ៤៥-លោកអនុសេនីយ៍ត្រី ហង្ស ពុទ្ធារិទ្ធិ | មន្ត្រី | សមាជិក |
| ៤៦-លោកអនុសេនីយ៍ត្រី សោម ស៊ីវីន | មន្ត្រី | សមាជិក |

អំពីតួនាទី និងភារកិច្ចៈ

- ទទួលបញ្ជីឈ្មោះស្ថាប័ន អង្គភាព និងចំនួនភ្ញៀវចូលរួមពីក្រុមការងារទំនាក់ទំនងភ្ញៀវជាតិ និងអន្តរជាតិ
- បែងចែកអាវជូនដល់គណៈអធិបតី និងភ្ញៀវអញ្ជើញចូលរួម
- សហការជាមួយពិធីការក្រសួងមហាផ្ទៃ រៀបចំប្លង់ និងបែងចែកកន្លែងអង្គុយរបស់គណៈអធិបតីភ្ញៀវជាតិ និងអន្តរជាតិ
- សហការជាមួយពិធីការក្រសួងមហាផ្ទៃ បែងចែកក្រុមការងារដើម្បីអញ្ជើញគណៈអធិបតី និងភ្ញៀវចូលតាមទីកន្លែងតាមប្លង់ដែលបានកំណត់
- រៀបចំប៉េងប៉ោង និងសារ សម្រាប់បង្ហោះ
- សហការជាមួយពិធីការក្រសួងមហាផ្ទៃរៀបចំអញ្ជើញថ្នាក់ដឹកនាំ អ្នកចូលរួម ដើម្បីអមគណៈអធិបតីក្នុងពិធីបង្ហោះប៉េងប៉ោង
- បែងចែកសំភារៈជូនភ្ញៀវជាតិ និងអន្តរជាតិអញ្ជើញចូលរួម
- សហការជាមួយពិធីការក្រសួងមហាផ្ទៃក្នុងការតាមដានត្រួតពិនិត្យការរៀបចំតុបតែងវេទិកាតុគណៈអធិបតី និងតុសុន្ទរកថា
- សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អំពីការសម្តែងសិល្បៈសម្រាប់កម្មវិធី
- ពិនិត្យ និងផ្តល់ earphone ជូនភ្ញៀវបរទេស
- ប្រធានក្រុមការងារត្រូវបែងចែកក្រុមការងារដើម្បីទទួលខុសត្រូវ
- អនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

ក្រុមទី ០៣ ៖ ក្រុមការងារព័ត៌មានវិទ្យា រូបភាព និងផ្សព្វផ្សាយ

អំពីសមាសភាពៈ

| | | |
|---|---|---|
| ១-លោកវរសេនីយ៍ទោ អ៊ុន មាន | អនុប្រធាននាយកដ្ឋាន | ប្រធាន |

២-លោកវរសេនីយ៍ទោ យឹម សំណាង អនុប្រធាននាយកដ្ឋាន អនុប្រធាន

៣-លោក វរសេនីយ៍ទោ អ៊ឹង ហាក់លៀង នាយការិយាល័យ អនុប្រធាន

៤-លោកវរសេនីយ៍ទោ អ៊ុច ចាន់ថា នាយរងការិយាល័យ សមាជិក

៥-លោកវរសេនីយ៍ទោ ជៀប នួច នាយរងការិយាល័យ សមាជិក

៦-លោកវរសេនីយ៍ទោ តាវ វិភត្តិ នាយរងការិយាល័យ សមាជិក

៧-លោកអនុសេនីយ៍ឯក អោក ភារិន នាយរងការិយាល័យ សមាជិក

អំពីតួនាទី និងភារកិច្ច៖

- គ្រប់គ្រងប្រព័ន្ធរូបភាព សំលេងក្នុងសាលប្រជុំ ក្នុងអំឡុងពិធី
- ត្រួតពិនិត្យប្រព័ន្ធរូបភាព ឧបករណ៍បំពងសំលេង មីក្រូហ្វូន......
- ផ្សាយបន្តរូបភាពពីខាងក្រៅសាលពិធី ទៅក្នុងសាលពិធី
- គ្រប់គ្រងអ្នកសារពត៌មាន ទូរទស្សន៍នៅក្នុងអំឡុងពិធី
- ចាត់ចែងថតរូបភាព និងវីដេអូក្នុងពិធី ទុកជាឯកសារ និងប្រើប្រាស់នៅក្នុងអគ្គលេខាធិការដ្ឋាន
- សហការជាមួយក្រសួងពត៌មាន ដើម្បីបំពេញការងារដែលមានការពាក់ព័ន្ធ
- អនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ក្រុមទី ០៤ ៖ ក្រុមការងាររបាយការណ៍**

អំពីសមាសភាព៖

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ទ្យូ ម៉ានីវ៉ា** អគ្គលេខាធិការរង ប្រធាន

២-លោក ប៉ុណ្ណ ចន្ថា អនុប្រធានលេខាធិការដ្ឋាន អនុប្រធាន

៣-លោកវរសេនីយ៍ទោ អ៊ុន សុខជា នាយការិយាល័យ សមាជិក

៤-**លោក អ៊ុំ ភាមិន្ទ** នាយការិយាល័យ សមាជិក

៥-លោកវរសេនីយ៍ទោ ផេង សេងលីម នាយរងការិយាល័យ សមាជិក

៦-លោកវរសេនីយ៍ទោ ឱក សត្យា នាយរងការិយាល័យ សមាជិក

៧-លោកវរសេនីយ៍ត្រី សៅ ស៊ីនួន នាយរងការិយាល័យ សមាជិក

៨-លោកវរសេនីយ៍ត្រី ម៉ុ ប៊ុន្នី នាយរងការិយាល័យ សមាជិក

អំពីមានតួនាទី និងភារកិច្ច៖

- ចងក្រងរបាយការណ៍សង្ខេបសម្រាប់កម្មវិធី
- រៀបចំឯកសារសម្រាប់ចែកជូនភ្ញៀវអញ្ជើញចូលរួម
- ថតចម្លងឯកសារ និងរៀបចំដាក់ចូលក្នុង Eco bag សម្រាប់ផ្តល់ជូនអ្នកចូលរួម
- ធ្វើរបាយការណ៍ និងកំណត់ហេតុកម្មវិធី
- អនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ក្រុមទី ០៥ ៖ ក្រុមការងារផ្គត់ផ្គង់ និងដឹកជញ្ជូន**

អំពីសមាសភាព៖

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន ទ្បី** អគ្គលេខាធិការរង ប្រធាន

២-លោកឧត្តមសេនីយ៍ត្រី អ៊ុច សម្បត្តិ អនុប្រធានលេខាធិការដ្ឋាន អនុប្រធាន

៣-លោកឧត្តមសេនីយ៍ត្រី សាង រំដោះ អនុប្រធាននាយកដ្ឋាន អនុប្រធាន

| | | |
|---|---|---|
| ៤-លោកវរសេនីយ៍ឯក រ៉ន សុភ័ក្រវឌ្ឍនា | អនុប្រធានលេខាធិការដ្ឋាន | អនុប្រធាន |
| ៥-កញ្ញាអនុសេនីយ៍ឯក សុខ ភារ៉ា | មន្ត្រី | សមាជិក |
| ៦-លោកស្រីអនុសេនីយ៍ឯក គុណ កែវរស្មី | មន្ត្រី | សមាជិក |
| ៧-កញ្ញាអនុសេនីយ៍ត្រី អុន កណ្ណិកា | មន្ត្រី | សមាជិក |
| ៨-លោកអនុសេនីយ៍ត្រី ជុំ សេន | មន្ត្រី | សមាជិក |
| ៩-លោកស្រីអនុសេនីយ៍ត្រី ថោង សុបុទុម | មន្ត្រី | សមាជិក |
| ១០-លោកអនុសេនីយ៍ត្រី សួន ផៃ | មន្ត្រី | សមាជិក |
| ១១-លោកអនុសេនីយ៍ត្រី នន់ ឧត្តម | មន្ត្រី | សមាជិក |
| ១២-កញ្ញាអនុសេនីយ៍ត្រី សំ ច័ន្ទធីតា | មន្ត្រី | សមាជិក |
| ១៣-លោកអនុសេនីយ៍ត្រី ឆន ដារ៉ារិទ្ធិ | មន្ត្រី | សមាជិក |
| ១៤-លោកអនុសេនីយ៍ត្រី ហុក ដារី | មន្ត្រី | សមាជិក |
| ១៥-លោកអនុសេនីយ៍ត្រី សេង សុភ័ក្រ | មន្ត្រី | សមាជិក |
| ១៦-កញ្ញាអនុសេនីយ៍ត្រី គឹម សុម៉ាលីន | មន្ត្រី | សមាជិក |
| ១៧-លោកអនុសេនីយ៍ត្រី យុន សុខា | មន្ត្រី | សមាជិក |
| ១៨-លោកអនុសេនីយ៍ត្រី ហង្ស ពុទ្ធារិទ្ធិ | មន្ត្រី | សមាជិក |
| ១៩-លោកអនុសេនីយ៍ត្រី សោម ស៊ីវរីន | មន្ត្រី | សមាជិក |

អំពីតួនាទី និងភារកិច្ចៈ

- រៀបចំឯកសារ និងសំភារៈផ្សេងៗដាក់ចូលក្នុង Eco bag
- ដឹកជញ្ជូនឯកសារ Eco bag អាវយឺត និងសំភារៈឧបករណ៍ផ្សេងៗទៀត បម្រើអោយការរៀបចំទិវាពីទីកន្លែងផ្សេងៗទៅកន្លែងប្រារព្ធពិធី
- រៀបចំទឹកសុទ្ធ ដាក់តាមកៅអីអង្គុយក្នុងសាល
- គ្រប់គ្រងសំភារៈ ឯកសារ អាវយឺត ទឹកសុទ្ធ នៅកន្លែងប្រារព្ធពិធី
- ប្រមូលសំភារៈ ឯកសារ អាវយឺត ទឹកសុទ្ធ ដែលសល់ពីការប្រើប្រាស់ក្រោយចប់ពិធីទៅទុក នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ វិញ ដើម្បីប្រើប្រាស់នៅពេលក្រោយ
- ធានាប្រសិទ្ធភាពនៃការប្រើប្រាស់សំភារៈ ឯកសារ អាវយឺត ទឹកសុទ្ធក្នុងអំឡុងពិធី
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

### ក្រុមទី ០៦ ៖ ក្រុមការងារចុះបញ្ជីវត្តមាន

អំពីសមាសភាពៈ

| | | |
|---|---|---|
| ១-លោក ឆេង វណ្ណា | អនុប្រធានលេខាធិការដ្ឋាន | ប្រធាន |
| ២-លោកវរសេនីយ៍ឯក នី គឹមស្រេន | អនុប្រធានលេខាធិការដ្ឋាន | អនុប្រធាន |
| ៣-លោកវរសេនីយ៍ទោ អ៊ុំ ធារ៉ែន | នាយការិយាល័យ | អនុប្រធាន |
| ៤-លោកវរសេនីយ៍ទោ ឯម សុជាតិ | នាយការិយាល័យ | អនុប្រធាន |
| ៥-កញ្ញាវរសេនីយ៍ទោ អ៊ឹង ស៊ូគីម | នាយរងការិយាល័យ | សមាជិក |
| ៦-លោកវរសេនីយ៍ទោ ជា ឆៃរី | នាយរងការិយាល័យ | សមាជិក |
| ៧-លោកវរសេនីយ៍ទោ ហ៊ី រតនៈ | នាយរងការិយាល័យ | សមាជិក |
| ៨-លោកវរសេនីយ៍ទោ ស្រី មករា | នាយរងការិយាល័យ | សមាជិក |

| | | |
|---|---|---|
| ៩-លោកវរសេនីយ៍ត្រី អ៊ុំ វណ្ណដា | នាយរងការិយាល័យ | សមាជិក |
| ១០-លោកវរសេនីយ៍ត្រី ជា ពិសិដ្ឋ | នាយផ្នែក | សមាជិក |
| ១១-លោកស្រីអនុសេនីយ៍ត្រី ច័ន្ទ បញ្ញា | មន្ត្រី | សមាជិក |
| ១២-លោកអនុសេនីយ៍ត្រី ផល គឹមសេង | មន្ត្រី | សមាជិក |

មានភារកិច្ចដូចតទៅ៖

- រៀបចំបញ្ជីវត្តមានសម្រាប់ប្រើប្រាស់ក្នុងអំឡុងពិធី
- រៀបចំតុ កៅអី ស្លាកសំគាល់ស្ថាប័ន អង្គភាព អង្គទូត រាជធានី-ខេត្ត បម្រើអោយការចុះឈ្មោះ
- សម្របសម្រួលអ្នកចូលរួមអោយចុះឈ្មោះតាមទីកន្លែងដែលបានកំណត់
- ប្រមូលបញ្ជីវត្តមានទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

ក្រុមទី ០៧ ៖ ក្រុមការងារសន្តិសុខ សណ្តាប់ធ្នាប់

អំពីសមាសភាព៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** | អគ្គលេខាធិការរង | ប្រធាន |
| ២-លោកវរសេនីយ៍ឯក មិន ប៊ុនរិទ្ធ | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣-លោកវរសេនីយ៍ឯក ហេង សំណាង | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៤-លោកវរសេនីយ៍ទោ គួច ក្រិត | នាយរងការិយាល័យ | សមាជិក |

មានភារកិច្ចដូចតទៅ៖

- សហការជាមួយនាយកដ្ឋានអង្គរក្ស ដើម្បីថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ទាំងក្នុង និងក្រៅបរិវេណប្រារព្ធពិធី
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ប្រការ ២ ៖** ក្រុមការងារនីមួយៗត្រូវរាយការណ៍អំពីវឌ្ឍនភាពការងារ និងលទ្ធផលសម្រេចបាន ជូនប្រធានគណៈកម្មការកណ្តាលរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដូចមានក្នុងសេចក្តីសម្រេចលេខ ២១៩/១៧ សសរ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧។

**ប្រការ ៣ ៖** លោកជំទាវ ឯកឧត្តម លោក-លោកស្រី ដែលមានឈ្មោះក្នុងប្រការ ០១ ត្រូវអនុវត្តភារកិច្ចអោយបានល្អ និងមានប្រសិទ្ធភាពចាប់ពីពេលចុះហត្ថលេខានេះតទៅ។

ថ្ងៃ ឆ្នាំ ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ គ.ស ២០១៧

អគ្គលេខាធិការ

__ចម្លងជូន៖__

- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កម្មវិធី ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៧
## នៅសាលមហោស្រពកោះពេជ្រ

- ម៉ោង ១៣:៣០-១៤:៣០នាទីរសៀល ៖ ជួបជុំសមាជិកអង្គមិទ្ទិញ
- ម៉ោង ១៤:៣០-១៤:៤៥នាទីរសៀល ៖ ភ្ញៀវកិត្តិយសអញ្ជើញមកដល់
- ម៉ោង ១៤:៤៥-១៥:០០នាទីរសៀល ៖ គណៈអធិបតីអញ្ជើញមកដល់
- ម៉ោង ១៥:០០-១៥:២០នាទីរសៀល ៖ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** និង **លោកជំទាវ** អញ្ជើញមកដល់
  - ពិធីបង្ហោះប៉េងប៉ោងនាំសារនៅខាងមុខសាលប្រារព្ធពិធី
  - គណៈអធិបតីអញ្ជើញចូលក្នុងសាលប្រារព្ធពិធី
- ម៉ោង ១៥:២០នាទីរសៀល ៖ ចាប់ផ្តើមកម្មវិធី
  - ប្រកាសហេតុ គោលបំណងនៃមិទ្ទិញ និងដំណើរការនៃកម្មវិធី
  - មតិស្វាគមន៍ និងរបាយការណ៍សង្ខេប របស់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
- ម៉ោង ១៥:៥០-១៦:១០នាទីរសៀល ៖ បង្ហាញខ្សែវីដេអូឃ្លីបនូវបទយកការណ៍ស្តីអំពីស្ថានភាពនៃអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា
- ម៉ោង ១៦:១០-១៦:៤៥នាទីរសៀល ៖ ការសម្តែងសិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ម៉ោង ១៦:៤៥នាទីរសៀល ៖ សុន្ទរកថា និងមតិដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
- ម៉ោង ១៧:០០នាទី ៖ បិទកម្មវិធី

(កម្មវិធីនេះនឹងអាចកែប្រែបានក្នុងករណីចាំបាច់)

ថ្ងៃ.12 វិ.2017

# អគ្គនាយកដ្ឋាន នៃក្រសួងមហាផ្ទៃ

## ១.អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានសវនកម្មទី១
- នាយកដ្ឋានសវនកម្មទី២
- នាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច

## ២.អគ្គលេខាធិការដ្ឋាន

- ខុទ្ទកាល័យរដ្ឋបាល
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានសរុប និងស្ថិតិ
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
- នាកយដ្ឋានព័ត៌មានវិទ្យា
- លេខាធិការដ្ឋានកិច្ចការទីប្រឹក្សា និងជំនួយការ

## ៣.អគ្គនាយកដ្ឋានរដ្ឋបាល

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត
- នាយកដ្ឋានកិច្ចការសមាគម និងគណៈបក្សនយោបាយ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានបណ្តុះបណ្តាល
- នាយកដ្ឋានមុខងារ និងធនធាន

## ៤.អគ្គស្នងការដ្ឋាននគរបាលជាតិ

- នាយកដ្ឋានបុគ្គលិក
- សេនាធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានសរុបផែនការ
- នាយកដ្ឋានវិទ្យុទាក់ទង
- នាយកដ្ឋានអក្សរសម្ងាត់
- អង្គភាពអន្តរាគមន៍
- ស្នងការដ្ឋានហិរញ្ញកិច្ច និងហិរញ្ញវត្ថុ

- អង្គភាពតម្រួតបទបញ្ជា
- នាយកដ្ឋាននគរបាលការពារ
- នាយកដ្ឋានកិច្ចការប៉ុស្តិ៍រដ្ឋបាល

**៥.អគ្គាធិការដ្ឋាន**

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានអធិការកិច្ច កិច្ចការរដ្ឋបាល
- នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការរដ្ឋបាល
- នាយកដ្ឋានអធិការកិច្ច កិច្ចការនគរបាលថ្នាក់កណ្តាល
- នាយកដ្ឋានអធិការកិច្ច កិច្ចការនគរបាលរាជធានី ខេត្ត
- នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនគរបាល

**៦.អគ្គនាយកដ្ឋានពន្ធនាគារ**

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានប្រតិបត្តិ
- នាយកដ្ឋានអប់រំ កែប្រែ និងស្តានីតិសម្បទា
- នាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ
- នាយកដ្ឋានសន្តិសុខពន្ធនាគារ

**៧.អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន៍ និងបច្ចេកវិទ្យា
- នាយកដ្ឋានជនបរទេសអន្តោប្រវេសន៍
- នាយកដ្ឋានជនបរទេសអន្តោប្រវេសន៍ និងជាអ្នកវិនិយោគឯកជន
- នាយកដ្ឋានច្រកទ្វារទី១
- នាយកដ្ឋានច្រកទ្វារទី២
- នាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី
- នាយកដ្ឋានជនភៀសខ្លួន

**៨.អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានអគ្រានុកូលដ្ឋាន
- នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- នាយកដ្ឋានលិខិតឆ្លងដែន

- នាយកដ្ឋានសញ្ញាតិ
- នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ
- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា

**៩.អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ**

- នាយកដ្ឋានរដ្ឋបាលសរុប
- នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្នែកសន្តិសុខសាធារណៈ
- នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែករដ្ឋបាលទូទៅ
- នាយកដ្ឋានភស្តុភារ និងសម្ភារៈបច្ចេកទេស
- នាយកដ្ឋានផ្សព្វផ្សាយអប់រំ
- នាយកដ្ឋានសុខាភិបាល
- នាយកដ្ឋានស្ថាបនា និងវិស្វកម្ម
- នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល
- នាយកដ្ឋានស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ

**១០.បណ្ឌិតសភានគរបាលកម្ពុជា**

- មន្ទីរចាត់ការ
- វិទ្យាស្ថានស្រាវជ្រាវ និងវិទ្យាសាស្ត្រនគរបាល
- វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល
- វិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ
- វិទ្យាស្ថានព័ត៌មានវិទ្យា និងភាសាបរទេស
- វិទ្យាស្ថានក្រោយបរិញ្ញាបត្រ
- មជ្ឈបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីពន្ធធនាគារ
- នាយកដ្ឋានបណ្តុះបណ្តាល
- សាលាមធ្យមវិជ្ជាជីវៈនគរបាល
- សាលាមធ្យមបច្ចេកទេស

**១១.ក្រុមប្រឹក្សានីតិកម្ម**

- នាយកដ្ឋានរដ្ឋបាលសរុប
- ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិនគរបាលជាតិ
- ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិរដ្ឋបាលស៊ីវិល
- ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិក្រសួងស្ថាប័ននានា
- ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

**១២.អគ្គនាយកដ្ឋានប្រយុទ្ធប្រឆាំងគ្រឿងញៀន** (heading as printed: ១២.អគ្គាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន)

- មានចំនួន ៧នាយកដ្ឋានចំណុះ

**១៣.នាយកដ្ឋានកណ្តាលនគរបាលព្រំដែន**

- នាយកដ្ឋាននគរបាលការពារព្រំដែនគោក
- នាយកដ្ឋាននគរបាលការពារព្រំដែនទឹក
- នាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន

**១៤.នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌**

- នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
- នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
- នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ
- នាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- មន្ទីរប្រឆាំងគ្រឿងញៀន

**១៥.នាយកដ្ឋានកណ្តាលសន្តិសុខ**

- នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
- នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
- នាយកដ្ឋានអង្គរក្ស
- នាយកដ្ឋានចារកម្ម
- នាយកដ្ឋានស៊ើបការខាងក្រៅ និងបច្ចេកទេស
- នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា

**១៦.នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ**

- នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ
- នាយកដ្ឋាននគរបាលទេសចរណ៍
- នាយកដ្ឋាននគរបាលការពារបេតិកភ័ណ្ឌ
- នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
- នាយកដ្ឋាននគរបាលបង្ការ ពន្លត់អគ្គីភ័យ និងសង្គ្រោះ

# កម្មវិធី ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៤

- ម៉ោង ១៣:៣០-១៤:៣០៖ ជួបជុំសមាជិកអង្គមិទ្ទិញ
- ម៉ោង ១៤:៣០-១៤:៤៥ ៖ ភ្ញៀវកិត្តិយសអញ្ជើញដល់
- ម៉ោង ១៤:៤៥-១៥:០០ ៖ គណៈអធិបតីអញ្ជើញដល់
- ម៉ោង ១៥:០០ ៖ សម្តេចក្រឡាហោម **ស ខេង** និងលោកជំទាវអញ្ជើញដល់
  - ពិធីបង្ហោះប៉េងប៉ោងនាំសារ នៅខាងមុខសាលប្រារព្ធពិធី
  - គណៈអធិបតីអញ្ជើញចូលក្នុងសាលប្រារព្ធពិធី
- ម៉ោង ១៥:១៥ ៖ ចាប់ផ្តើមកម្មវិធី
  - ប្រកាសហេតុ គោលបំណងនៃមិទ្ទិញ និងដំណើរការនៃកម្មវិធី
  - មតិស្វាគមន៍ និងរបាយការណ៍សង្ខេប (លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ)
- ម៉ោង ១៥:៣៥-១៦:០០ ៖ ខ្សែវីដេអូបទយកការណ៍ ស្តីពីអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា
- ម៉ោង ១៦:០០-១៦:៣០ ៖ ការសម្តែងសិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ម៉ោង ១៦:៣០ ៖ មតិសំណេះសំណាល និងអនុសាសន៍ដឹកនាំរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ម៉ោង ១៧:០០ ៖ បិទកម្មវិធី

(សូមពាក់អាវយឺតដែលកម្មវិធីបានផ្តើជូន)

**** កម្មវិធីនេះនឹងអាចកែប្រែបានក្នុងករណីចាំបាច់*

## *Program for National Day of Anti-Human Trafficking*

- 13:30-14:30: Arrival of participants
- 14:30-14:45: Arrival of distinguished guests
- 14:45-15:00: Arrival of Delegates
- 15:00 : Arrival of **Samdech Krolahom SAR KHENG** and **Lok Chum Teav**
  - Flying message balloons in front of the Meeting Hall
  - Delegates enter the Meeting Hall
- 15:15: Introduction
  - Announce the purpose of the meeting program
  - Welcome Remarks and report by Her Excellency **CHOU BUN ENG**, Deputy Chair of the National Committee for Counter Trafficking in Persons (N.C.C.T)
- 15:35-16:00: Documentary film on the Situation of trafficking in persons and the response of the Royal Government of Cambodia.
- 16:00-16:30: Arts Performance by the Ministry of Culture and Fine Arts
- 16:30: Special Remarks and Recommendations by Samdech Krolahom **SAR KHENG**, Deputy Prime Minister, Minister of Interior, Chairperson of the National Committee for Counter Trafficking in Persons
- 17:00: Closing.

(Please wear the Event's T-shirt provided)

**** This program is tentative*

ពាក្យស្លោកសម្រាប់ ពិធីទិវាជាតិ១២ធ្នូ២០១៧ ដែលនឹងប្រព្រឹត្តទៅ នៅសាលសន្និសីទ និងពិព័រណ៍កោះពេជ្រ k(2017)

ស្នើសុំការចូលរួមឧបត្ថម្ភគាំទ្រពីសាលារាជធានីភ្នំពេញ៖
បដា ៤០ សម្រាប់ ចងតាមដងវិថីសហភាពសូវៀត ពីព្រលានយន្តហោះ មក ដល់មហាវិថីព្រះនរោត្តម ដងមហាវិថី ព្រះនរោត្តម និងភ្ជាប់ទៅ មជ្ឈមណ្ឌល ពិពរណ៍ និងមហោស្រពកោះពេជ្រ។

<u>តាមបណ្ដាខេត្ត៖</u>
អាចជ្រើសរើសពាក្យស្លោកទាំងនេះ ប្រើប្រាស់ សម្រាប់ពិធី ឬផ្សព្វផ្សាយតាមបណ្ដាខេត្តនីមួយៗ។

1. អបអរសាទរ! ទិវាជាតិ លើកទី១១ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧! ២!
2. Congratulations! The Celebration of the 11th National Day on Anti-Human Trafficking, December 12, 2017!
3. រួមគ្នាបង្កើតប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស
4. Together create safety net and enforce law practices for protecting our people from trafficking in persons
5. រួមគ្នាបង្ការទប់ស្កាត់! ជួយជនរងគ្រោះ! បង្ក្រាប និងផ្ដន្ទាទោសជនល្មើសឲ្យបានដាច់ខាត!
6. ពង្រឹងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍មិនប្រក្រតីឆ្លងកាត់ព្រំដែន! បង្កើនជម្រើសការងារក្នុងស្រុក ដើម្បីសុវត្ថិភាពពលករ!
7. អំពើជួញដូរមនុស្ស គឺជាការរំលោភសិទ្ធិមនុស្ស យ៉ាងធ្ងន់ធ្ងរ!- Trafficking in persons is a grave Human Rights Violation!!
8. រាជរដ្ឋាភិបាលកម្ពុជាប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ
9. សុវត្ថិភាពជាចម្បង! គិតឲ្យច្បាស់សិន កុំចាកចេញ ឆ្លងដែនដោយខុសច្បាប់!
10. អ្នកជាមនុស្សសំខាន់សម្រាប់គ្រួសារ និងប្រទេសជាតិ មិនមែនជាទំនិញសម្រាប់ ឧក្រិដ្ឋជនជួញដូរមនុស្សទេ!
11. ធ្វើការក្នុងស្រុកក៏សុខសប្បាយ! បើទៅធ្វើការឆ្ងាយក៏ត្រូវមានសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរ!
12. កម្ពុជា ជាព្រះរាជាណាចក្រអច្ឆរិយៈ! មានសម្បត្តិវប្បធម៌ និងធម្មជាតិស្រស់បំព្រង មិនមែនជាកន្លែងសម្រាប់ទេសចរណ៍ផ្លូវភេទទេ!
13. ជនណាជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទលើកុមារ គឺជា ឧក្រិដ្ឋជន ដែលត្រូវផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ!
14. Trafficking in persons is a Crime, traffickers shall be punished seriously, according to Cambodian Law!
15. No Child Sex Tourism! No Child Sexual Abuse in Cambodia. Perpetrators shall be punished seriously!
16. កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ ការងារសំណង់នៅកម្ពុជា ត្រូវការអ្នក ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិយើង!
17. នាំគ្នាបង្កើនផលិតផលក្នុងស្រុកគ្រប់ប្រភេទ ប្រកបដោយគុណភាព សម្រាប់ស្វាគមន៍ទេសចរណ៍ដែលមកទស្សនាព្រះរាជាណាចក្រកម្ពុជាយើង!
18. រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដើម្បីកសាងអនាគតល្អសម្រាប់ប្រជាជន និងប្រទេសជាតិយើង!
19. ជនងាយរងគ្រោះ និងជនរងគ្រោះ ត្រូវការជំនួយ និងការគាំទ្រពីយើងទាំងអស់គ្នា!
20. បុរស ស្ត្រី យុវវ័យ និងកុមារ ជាធនធានដ៏មានតម្លៃរបស់ជាតិ សូមចូលរួម ថែរក្សា ការពារ កុំឲ្យក្លាយជាកម្មវត្ថុរបស់ ឧក្រិដ្ឋជនជួញដូរមនុស្ស!
21. រួមគ្នាលើកកម្ពស់សីលធម៌សង្គម និងការអនុវត្តច្បាប់ ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់រូបភាព
22. ផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ ដល់ជនទាំងឡាយណា ដែលជាមេខ្លោង អ្នកសមគំនិត អ្នកផ្ដល់មធ្យោបាយ ជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ

23. លុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអាជីវកម្មផ្លូវភេទលើកុមារ ឬអនីតិជន នៅកម្ពុជា។

24. អ្នកធ្វើអាជីវកម្មផ្លូវភេទលើកុមារ នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ១៥ឆ្នាំ។

25. បើបានឮ បានឃើញ ឬសង្ស័យថាមានអំពើរំលោភបំពាន ឬជួញដូរមនុស្ស សូមទាក់ទងលេខៈ ១១៧ ឬ ១១៨ ឬ ១២៨៨ ឬ ១២៩៩

«រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស»

"Together, We Combat Human Trafficking"

www.ncct.gov.kh

(2017)

អបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

Celebration of the National Anti-Human Trafficking Day

**ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ**
**និង លោកជំទាវ**

**Presided over by**
**Samdech Krolahom SAR KHENG Deputy Prime Minister**
**Chairperson of NCCT and Lok Chum Teav**

នៅសាលមហោស្រពកោះពេជ្រ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង៣:០០រសៀល

At Koh Pich Conference Hall, 12 December 2017 at 3:00pm

ធ្នូ (2017)

(23)

## កម្មវិធី ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ម៉ោង ១៣:៣០-១៤:៣០៖ ជួបជុំសមាជិកអង្គមិទ្ទិញ
- ម៉ោង ១៤:៣០-១៤:៤៥៖ ភ្ញៀវកិត្តិយសអញ្ជើញដល់
- ម៉ោង ១៤:៤៥-១៥:០០៖ គណៈអធិបតីអញ្ជើញដល់
- ម៉ោង ១៥:០០ ៖ សម្តេចក្រឡាហោម **ស ខេង** និងលោកជំទាវអញ្ជើញដល់
  - ពិធីបង្ហោះប៉េងប៉ោងនាំសារ នៅខាងមុខសាលប្រារព្ធពិធី
  - គណៈអធិបតីអញ្ជើញចូលក្នុងសាលប្រារព្ធពិធី
- ម៉ោង ១៥:១៥ ៖ ចាប់ផ្តើមកម្មវិធី
  - ប្រកាសហេតុ គោលបំណងនៃមិទ្ទិញ និងដំណើរការនៃកម្មវិធី
  - មតិស្វាគមន៍ និងរបាយការណ៍សង្ខេប (លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ)
- ម៉ោង ១៥:៣៥-១៦:០០៖ ខ្សែវីដេអូបទយកការណ៍ ស្តីពីអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា
- ម៉ោង ១៦:០០-១៦:៣០៖ ការសម្តែងសិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ម៉ោង ១៦:៣០ ៖ មតិសំណេះសំណាល និងអនុសាសន៍ដឹកនាំរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ម៉ោង ១៧:០០ ៖ បិទកម្មវិធី

(សូមពាក់អាវយឺតដែលកម្មវិធីបានផ្តល់ជូន)

*** កម្មវិធីនេះនឹងអាចកែប្រែបានក្នុងករណីចាំបាច់

## Program for National Day of Anti-Human Trafficking

- 13:30-14:30: Arrival of participants
- 14:30-14:45: Arrival of distinguished guests
- 14:45-15:00: Arrival of Delegates
- 15:00 : Arrival of **Samdech Krolahom SAR KHENG** and **Lok Chum Teav**
  - Flying message balloons in front of the Meeting Hall
  - Delegates enter the Meeting Hall
- 15:15: Introduction
  - Announce the purpose of the meeting program
  - Welcome Remarks and report by Her Excellency **CHOU BUN ENG,** Deputy Chair of the National Committee for Counter Trafficking in Persons (N.C.C.T)
- 15:35-16:00: Documentary film on the Situation of trafficking in persons and the response of the Royal Government of Cambodia.
- 16:00-16:30: Arts Performance by the Ministry of Culture and Fine Arts
- 16:30: Special Remarks and Recommendations by Samdech Krolahom **SAR KHENG**, Deputy Prime Minister, Minister of Interior, Chairperson of the National Committee for Counter Trafficking in Persons
- 17:00: Closing.

(Please wear the Event's T-shirt provided)

**** This program is tentative*

ឧបសម្ព័ន្ធ - (2017)

(24)

(25)

# គោលបំណងនៃការប្រារព្ធទិវាជាតិ

## Purpose of the National Day for Anti-Human Trafficking

- បង្ហាញពីឆន្ទៈដ៏មុះមុតរបស់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប ក្នុងការពង្រឹងប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបពីអំពើជួញដូរមនុស្ស ។
- To highlight the Strong Commitment of the Royal Government of Cambodia and its people in Strengthening Safety Net and Enhancing Law Enforcement to protect all people from Trafficking in persons.

(2017)

ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

រួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាព និង ពង្រឹងការអនុវត្តច្បាប់

ទិវា ១២ធ្នូ លើកទី ១១

ប្រឆាំងអំពើជួញដូរមនុស្ស

ឆ្នាំ ២០១៧

ដើម្បីការពារមនុស្សពីអំពើជួញដូរ

# គ.ជ.ប.ជ

# V VIP

# ២០១៧

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

(បណ្ណ [illegible])

(26)

## **មតិស្វាគមន៍** ៤

ថ្លែងដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

ក្នុងពិធីបើកកម្មវិធី «ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ»

នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ

ថ្ងៃទីទី ១២ ខែធ្នូ ឆ្នាំ២០១៧

- សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរពសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតី តេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ ជាប្រធាន អនុប្រធានគណៈកម្មាធិការ និងជាសមាជិកដ៏ឧត្តុង្គឧត្តមនៃព្រឹទ្ធសភា រដ្ឋសភា និងសមាជិក រាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានា នៃបណ្ដាប្រទេសជាមិត្ត
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា អស់លោក លោកស្រីភ្ញៀវកិត្តិយសជាតិ អន្តរជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- សិស្សានុសិស្ស និយោជក កម្មករនិងបងប្អូនជនរួមជាតិ និងអង្គពិធីទាំងមូល ជាទីគោរពរាប់អាន !

នៅក្នុងឱកាសនៃការប្រារព្វទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ ដ៏អធឹកអធមនេះ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពអនុញ្ញាតក្នុងនាម គណៈកម្មការរៀបចំពិធី សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានជាអធិបតីដ៏ខ្ពង់ខ្ពស់ របស់ **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងដ៏ខ្ពង់ខ្ពស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងសូមថ្លែងអំណរព្រះគុណ និងអំណរគុណ ចំពោះការយាង និងនិមន្តចូលរួម ពីព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងការអញ្ជើញចូលរួម ផ្ដល់កិត្តិយសពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំគ្រប់ស្ថាប័ន រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល តំណាងអង្គទូត និងស្ថាន

បេសកកម្មនានានៃប្រទេសជាមិត្តដែលមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ តំណាងអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ បណ្ឌិត សាស្ត្រាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា សាកលវិទ្យាល័យរដ្ឋ និងឯកជន ឯកឧត្តម លោកជំទាវ អគ្គស្នងការ អគ្គស្នងការរង មេបញ្ជាការ មេបញ្ជាការរង លោកជំទាវអភិបាល អភិបាលរងរាជធានីខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ កងកម្លាំងគ្រប់ប្រភេទ ទាំងជើងទឹក ជើងគោក ជើងអាកាស លោក លោកស្រីជាតំណាងផ្នែកឯកជន សង្គមស៊ីវិល តំណាងកម្មករនិយោជិត បុព្វជិតសាសនាគ្រប់និកាយ ភ្ញៀវជាតិ អន្តរជាតិ យាយជី តាជី ក្មួយៗយុវជន យុវនារី និស្សិត សិស្សានុសិស្ស ក្រុមយុវជនកាយរឹទ្ធ និងយុវជនកាកបាតក្រហមកម្ពុជា ដែលសរុបប្រមាណជាង ៣០០០នាក់ បានផ្តល់កិត្តិយស និងសម្តែងអំពីការយកចិត្តទុកដាក់ខ្ពស់ចំពោះកម្មវិធី ស្វែងយល់ និងចូលរួមប្តេជ្ញាចិត្តជាមួយគ្នាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនាថ្ងៃដ៏នក្ខត្តរឹកនេះ។

ឱកាសជួបជុំដ៏មានអត្ថន័យនេះ គឺក្នុងគោលបំណងបញ្ជាក់ជូនជនរួមជាតិ និងសហគមន៍អន្តរជាតិឲ្យបានជ្រាបថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅតែយកចិត្តទុកដាក់កាន់តែខ្លាំងក្លាក្នុងការការពារប្រជាពលរដ្ឋ និងប្រទេសជាតិពីភាពរងគ្រោះទាំងឡាយដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឲ្យមានវិនាសកម្ម ជាថ្មីដល់មនុស្សជាតិ ហើយបាន និងកំពុងក្លាយជាទាសភាពសម័យទំនើបគួរឲ្យភ័យខ្លាច និងស្អប់ខ្ពើម ។ យុទ្ធនាការនេះ នឹងបន្តធ្វើយ៉ាងគគ្រឹកគគ្រេង តាមបណ្តាខេត្ត និងតាមប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីបញ្ជ្រាបការយល់ដឹងទៅដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស ។

អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទគឺជាបរិបទសាកល ដែលនៅតែបន្តកើតមានអាស្រ័យកត្តាសំខាន់បី គឺ ការអប់រំសង្គម ការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស ។ រូបភាពនៃអំពើជួញដូរមនុស្ស មិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក្នុងឆ្នាំកន្លងទៅ ក៏មានលេចចេញនូវបាតុភាពមួយចំនួន ដែលមានទំនោរទៅរកអំពើជួញដូរសរីរាង្គ និង បទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែលហៅថា បទអន្តរការីនៃអំពើពពោះជំនួស ។ នេះជាកង្វល់ ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចាំបាច់ត្រូវដាក់វិធានការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបឲ្យបានទាន់ពេល និងបានកសាងច្បាប់ បទដ្ឋានគតិយុត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បីជៀសវាងការរីកដុះដាលនៃបទល្មើស ដែលនាំឲ្យបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងដល់ជីវិតមនុស្ស ។

ការធ្វើទេសន្តរប្រវេសន៍ គឺជាជម្រើសរបស់ប្រជាពលរដ្ឋ ដែលមិនអាចហាមឃាត់បាន ហើយក៏មិនមែនសុទ្ធតែជាហានិភ័យដែលគួរជៀសវាងដែរ ។ ជាគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺ ផ្តល់ឱកាសជូនប្រជាពលរដ្ឋក្នុងការងារ បង្កើនប្រាក់ចំណូល ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស ។ ពលករមួយចំនួនធំ បានទទួលកម្រៃល្អ និងអាចលើកកម្ពស់ជីវភាពតាមការរំពឹងទុក និងទទួលបាននូវជំនាញ បច្ចេកទេសកាន់តែប្រសើរគួរឲ្យមោទនៈ ។ ប៉ុន្តែអ្វីដែលជាការបារម្ភនោះ គឺការធ្វើទេសន្តប្រវេសន៍ដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់ និងមិនមានការគ្រប់គ្រង



(28)

ច្បាស់លាស់ ដែលនាំឲ្យប្រឈមនឹងហានិភ័យដោយអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្ស ។ ចំនួនប្រជាពលរដ្ឋកម្ពុជា ដែលបានធ្វើទេសន្តរប្រវេសន៍ ឬចំណាកស្រុកឆ្លងដែនមិនប្រក្រតី មិនមានឯកសារផ្លូវច្បាប់ត្រឹមត្រូវ បានកើនឡើងគួរឲ្យកត់សម្គាល់ ពីមួយឆ្នាំទៅមួយឆ្នាំ ។ ពលករទាំងនោះ ជារឿយៗ ត្រូវទទួលរងនឹងការកេងប្រវ័ញ្ចគ្រប់រូបភាព នៅគ្រប់តំណាក់កាលក្នុងវដ្តនៃទេសន្តរប្រវេសន៍ តាំងពីពេលចេញដំណើរ ការឆ្លងដែន រហូតដល់កន្លែងការងារ ។ មួយចំនួន បានទទួលរងគ្រោះដោយការចាប់ឃាត់ខ្លួនដាក់ពន្ធនាគារ ការផាកពិន័យ ការចាប់បញ្ជូនត្រឡប់ ការមិនផ្តល់ប្រាក់កម្រៃពលកម្មពេញលេញ ឬការបញ្ជូនបន្តទៅធ្វើការពីកន្លែងមួយ ទៅកន្លែងមួយ ឬទៅឆ្ងាយឯនាយសមុទ្រមិនអាចទំនាក់ទំនងទៅគ្រួសារបាន ការដកហូតលិខិតសម្គាល់អត្តសញ្ញាណឬប្តូរអត្តសញ្ញាណ ការប្រមាថមាក់ងាយ ទារុណកម្មធ្ងន់ធ្ងរ បាត់ដំណឹង ឬបាត់បង់ជីវិត ជាបន្តបន្ទាប់ ។ មកដល់បច្ចុប្បន្ននេះ ពលករកម្ពុជាដែលបាន និងកំពុងធ្វើការនៅក្រៅប្រទេស មានរហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ និងទាំងមិនស្របច្បាប់ ដែលជាចំនួនដ៏ច្រើន គឺជិត ១០ភាគរយ នៃចំនួនប្រជាជនសរុប និងប្រមាណជា ១៤% នៃប្រជាពលរដ្ឋដែលពេញកម្លាំងពលកម្ម និងដែលចាំបាច់ត្រូវពង្រឹងការគ្រប់គ្រង ដើម្បីលើកកម្ពស់សក្តានុពលធនធាននៃកម្លាំងពលកម្មទេសន្តរប្រវេសន៍ដ៏ច្រើនលើសលប់នេះ ។

ក្នុងតំណាក់កាលនៃការរឹតបន្តឹងច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍របស់រាជរដ្ឋាភិបាលថៃ ចំពោះពលករបរទេសដែលរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ បានចោទជាបញ្ហាថ្មីមួយ ដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងសហការដោះស្រាយយ៉ាងយកចិត្តទុកដាក់ ក្នុងការសម្របសម្រួលផ្តល់ភាពស្របច្បាប់ជូនពលករខ្មែរ ។ ការពន្យារពេលអនុវត្តច្បាប់រយៈពេល៦ខែ និងបន្ថែមបីខែទៀតដើម្បីឲ្យពលកររៀបចំបំពេញបែបបទឯកសារស្របច្បាប់ គឺជាដំណោះស្រាយដ៏ល្អមួយ សម្រាប់ដោះស្រាយភាពស្របច្បាប់ដល់ពលករទេសន្តរប្រវេសន៍ដែលបាន និងកំពុងស្នាក់នៅ និងធ្វើការដោយខុសច្បាប់ក្នុងប្រទេសថៃ ។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះ នឹងមិនអាចឆ្លើយតបនឹងតម្រូវការដ៏ច្រើនលើសលប់ របស់ពលករបានទាំងអស់ឡើយ ។ ពលករនៅតែព្យាយាម សម្ងំលាក់ខ្លួនធ្វើការដោយខុសច្បាប់ រង់ចាំការផ្តល់ភាពស្របច្បាប់ក្នុងប្រទេសគោលដៅ ជាជាងការបំពេញបែបបទច្បាប់មុនពេលចាកចេញតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈ ទ្វេភាគី ។ ទន្ទឹមនឹងនោះ ក៏មានជនខិលខូច និងឧក្រិដ្ឋជនជួញដូរ និងរត់ពន្ធមនុស្ស ឆ្លៀតឱកាសបោកប្រាស់ និងកេងប្រវ័ញ្ចតាមគ្រប់វិធី ។ គឺក្នុងតំណាក់កាលនេះហើយ ដែលជាហានិភ័យរបស់ពលករទេសន្តរប្រវេសន៍បាន និងកំពុងជួបប្រទះ ។

ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី និង លោកជំទាវជាទីគោរពដ៏ខ្ពង់ខ្ពស់** ឯកឧត្តម លោកជំទាវ លោកលោកស្រី និងក្មួយៗ ជាទីគោរពរាប់អាន

ស្ថិតក្នុងស្ថានភាពនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីបណ្តាក្រសួងស្ថាប័នជាសមាជិកគ្រប់លំដាប់ថ្នាក់ ព្រមទាំងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា បាន និងកំពុងរួមដៃគ្នា ធ្វើសកម្មភាពឥតឈប់ឈរ ប្រកបដោយការលះបង់ខ្ពស់ ក្រោមការ

ដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបន្តខិតខំពុះពារ គ្រប់ឧបសគ្គនិងការលំបាកនានា ដើម្បីដោះស្រាយបញ្ហាដ៏ក្តៅគគុកនេះអស់ពីសមត្ថភាព ។

ក្នុងកម្មវិធីជួបជុំដ៏មានសារៈសំខាន់នេះ គណៈកម្មាធិការជាតិ បានដាក់ចេញនូវប្រធានបទគោលដ៏សំខាន់មួយគឺ ៖ **«រួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបពីអំពើជួញដូរមនុស្ស»** ដើម្បីជាយុទ្ធនាការដ៏ទូលំទូលាយ ផ្សព្វផ្សាយការយល់ដឹង និងអំពាវនាវការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ និងជនរួមជាតិ គ្រប់ទិសទី ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់គ្នា ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណ និងអំណរគុណដោយគោរព ចំពោះ **សម្តេចក្រឡាហោម ប្រធានគណៈកម្មាធិការជាតិ** ដែលបានដឹកនាំ ចង្អុលទិសឲ្យថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការជាតិគ្រប់លំដាប់ថ្នាក់និងដៃគូជាតិ និងអន្តរជាតិទាំងអស់បានខិតខំប្រឹងប្រែង និងចូលរួមអនុវត្តសកម្មភាពព្រមៗគ្នា ដោយមិនខ្លាចនឿយហត់ រហូតទទួលបាននូវលទ្ធផលគួរឲ្យកត់សម្គាល់កន្លងមក ។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមទាំងកម្លាំងកាយចិត្ត និងធនធាន និងបច្ចេកទេសពីក្រសួងស្ថាប័នពាក់ព័ន្ធ ក៏ដូចជាវិស័យឯកជន អង្គការដៃគូជាមិត្ត ដែលញ៉ាំងឲ្យកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្សនាថ្ងៃនេះប្រព្រឹត្តទៅយ៉ាងអធឹកអធមក្រៃលែង ។ សូមថ្លែងអំណរគុណដល់ ក្រុមការងារទូរទស្សន៍ BTV News និង PNN ដែលបានចូលរួមសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សយ៉ាងសកម្មផលិតជាបទយកការណ៍ដ៏មានសារៈសខាន់ ដោយបានឆ្លុះបញ្ចាំងពីសភាពការណ៍ពិតនៅកម្ពុជាពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ជាតិ និងកិច្ចការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស ។

ជាថ្មីម្តងទៀត ជំនួសមុខអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មការរៀបចំកម្មវិធី នាងខ្ញុំសូមគោរពជូនពរបវរមហាប្រសើរ ជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី ព្រមទាំង លោកជំទាវ សូមប្រកបដោយជោគជ័យ សិរីមង្គលវិបុលសុខ គ្រប់ប្រការ សូមថ្វាយ និងប្រគេនពរ ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ជូនពរឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សមាជិក សមាជិកានៃអង្គពិធីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់កិត្តិយសក្នុងកម្មវិធីប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ នាថ្ងៃនេះ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ! សូមអរគុណ!**



(30)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សុន្ទរកថា k

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គ.ជ.ប.ជ

ក្នុងទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧

នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ

- សូមថ្វាយបង្គំ ព្រះថេរានុត្ថេរគ្រប់ព្រះអង្គ
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ឬតំណាងអង្គទូតនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាកលវិទ្យាធិការ លោកលោកស្រី ជានាយក នាយិកា បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស
- អ្នកឧកញ៉ា លោកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងវិស័យឯកជន
- កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- តាជី យាយជី និងបងប្អូនជនរួមជាតិ ជាទីស្នេហា

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមជាអធិបតីក្នុងឱកាសជួបជុំដ៏មហោឡារិក នាទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នាថ្ងៃនេះ ។ វត្តមានដ៏ច្រើនកុះករ របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗ នាពេលនេះ គឺ ជាសាក្ខីភាព ដែលបង្ហាញយ៉ាងច្បាស់អំពីការយកចិត្ត

ទុកដាក់ខ្ពស់ ប្រកបដោយស្មារតីទទួលខុសត្រូវរបស់យើងទាំងអស់គ្នា ទាំងថ្នាក់ដឹកនាំ ទាំងប្រជាពលរដ្ឋកម្ពុជា ទាំងស្ថាប័នរដ្ឋ ស្ថាប័នឯកជន ក៏ដូចជាសហគមន៍អន្តរជាតិ ក្នុងការរួមគ្នាការពារមនុស្សជាតិ ពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងប្រឆាំងដាច់ខាតរាល់ទម្រង់នៃការរំលោភបំពាន និងកេងប្រវ័ញ្ច លើមនុស្សគ្រប់រូបភាព ។

នៅក្នុងទិវាដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមបញ្ជាក់ អំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជាជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាល បានចាត់ទុកអំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋ និងប្តេជ្ញាចិត្តទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះឲ្យបានខ្លាំងក្លា ដោយមិនអនុញ្ញាតឲ្យជនល្មើសមានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ ។

ដូចព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនប្រជាពលរដ្ឋ ក្មួយៗនិស្សិត សិស្សានុសិស្ស បានជ្រាបតាមរយៈរបាយការណ៍ របស់លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ និងបទយកការណ៍ដែលបានបង្ហាញជូនក្នុងពេលកន្លងទៅនេះរួចហើយថា បទល្មើសជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មឆ្លងដែន ដែលកាន់តែស្រួចស្រាល និងគ្រោះថ្នាក់ជាទីបំផុតដល់មនុស្សជាតិ ជាពិសេស ក្នុងចំណោមពលករទេសន្តរប្រវេសន៍ ដែលបានចាកចេញទៅធ្វើការងារនៅក្រៅប្រទេស និងជនភៀសខ្លួន ទាំងក្មេង ចាស់ ប្រុសស្រី ដោយមិនរើសមុខ ។

ជនល្មើសកាន់តែព្រហើន មានកលល្បិចកាន់តែខ្ពស់ គួបផ្សំនឹងប្រព័ន្ធទំនាក់ទំនងកាន់តែទំនើប ដែលបង្កការលំបាកដល់សមត្ថកិច្ច និងរដ្ឋាភិបាលនៃបណ្តាប្រទេសពាក់ព័ន្ធក្នុងការបង្ក្រាប ដើម្បីផ្តន្ទាទោសជនល្មើសឲ្យបានទាន់ពេលវេលា ។ ទោះបីជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាមិនបានព្រងើយកន្តើយឡើយ ផ្ទុយទៅវិញ យើងបានរិះរកគ្រប់វិធានការ និងវិធីសាស្ត្រ ដើម្បីការពារប្រជាពលរដ្ឋពី បទល្មើសដ៏ស្មុគ្រស្មាញនេះ ។ គណៈកម្មាធិការជាតិ បានសំរេចការអនុវត្តយុទ្ធសាស្ត្រទាំងបួន គឺ ការងារបង្ការទប់ស្កាត់ ការការពារជនរងគ្រោះ ការអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហការ ក្នុងការរៀបចំ និងជំរុញការរៀបចំច្បាប់ គោលនយោបាយនានាឱ្យកាន់តែមានប្រសិទ្ធិភាព ។

ក្នុងពេលកន្លងទៅព្រះរាជាណាចក្រកម្ពុជា បានដោះស្រាយបញ្ហាទាំងនេះយ៉ាងយកចិត្តទុកដាក់ ដើម្បីរក្សានូវតុល្យភាពនៃតម្រូវការ និងការផ្គត់ផ្គង់ ព្រមទាំងពង្រឹងសន្តិសុខដល់ប្រជាពលរដ្ឋ និងភ្ញៀវបរទេសទាំងឡាយ ឲ្យស្នាក់នៅក្នុងកម្ពុជាប្រកបដោយភាពកក់ក្តៅ មានសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្ត ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ការលំបាក និងភាពប្រឈមនៃប្រទេសទាំងសងខាង គឺប្រទេសបញ្ជូន និងប្រទេសទទួលក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ និងបទល្មើសទាំង ឡាយ ដែលកើតឡើងក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ និងនៅក្នុងប្រទេស

គោលដៅ ។ ទេសន្តរប្រវេសន៍ខុសច្បាប់នៅក្នុងប្រទេសគោលដៅ គឺជាការស្នាក់នៅ និងធ្វើការដោយខុសច្បាប់ នោះជាការប្រថុយប្រថាននឹងគ្រោះថ្នាក់ និងការខាតបង់ យ៉ាងធ្ងន់ធ្ងរដល់បុគ្គលអ្នកធ្វើទេសន្តរប្រវេសន៍ និងដល់ក្រុមគ្រួសារមួយចំនួន ។ ការលំបាកទាំងនេះ មិនអាចភាគីប្រទេសតែមួយដោះស្រាយបានឡើយ ហេតុនេះទើបបានជាទាមទារឲ្យមានកិច្ចសហការ និងចាំបាច់ត្រូវពង្រឹងបន្ថែមទៀត នូវកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហារួមគ្នាប្រកបដោយការទទួលខុសត្រូវ និងសមធម៌ ។

ប្រទេសដែលមានការពាក់ព័ន្ធ ចាំបាច់ត្រូវឯកភាពគ្នា ដើម្បីអនុវត្តបែបបទនីតិវិធី ដែលបានព្រមព្រៀងគ្នាក្នុងអនុស្សរណៈ ។ ក្នុងនាមជាប្រទេសបញ្ជូន រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវបទដ្ឋានគតិយុត្តិជាច្រើន ដែលក្នុងនោះ រួមទាំងការអនុញ្ញាតឲ្យមានក្រុមហ៊ុន ជាច្រើនទទួលបានអាជ្ញាប័ណ្ណដើម្បីធ្វើការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនដោយស្របច្បាប់ ។ តែទន្ទឹមនឹងនោះក៏ការអនុវត្តនៅតែមានភាពខ្វះចន្លោះទាំងសងខាង ដែលនាំឲ្យបញ្ហាកាន់តែស្មុគស្មាញ ។ ការដោះស្រាយដោយផ្តល់ភាពស្របច្បាប់ នៅប្រទេសគោលដៅ គ្រាន់តែជាដំណោះស្រាយបណ្តោះអាសន្នតែប៉ុណ្ណោះ ។ បន្ទាប់ពីការដោះស្រាយនេះរួច ចាំបាច់ត្រូវតែពិភាក្សាគ្នាឡើងវិញ ដើម្បីធ្វើកិច្ចការបន្តទៀត ឲ្យរលូនជាមួយគ្នា និងដើម្បីជាបទដ្ឋានស្តង់ដាមួយ ដែលងាយស្រួលក្នុងការអនុវត្ត និងជៀសវាងការហូរចូលនៃទេសន្តរប្រវេសន៍មិនប្រក្រតី ដែលនាំឲ្យមានភាពប្រឈមកើតឡើងជាថ្មីទៀត ។

ព្រះរាជាណាចក្រកម្ពុជា គាំទ្រការធ្វើទេសន្តរប្រវេសន៍ ដែលមានសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដើម្បីបញ្ចៀសហានិភ័យរបស់ពលករ ពីការកេងប្រវ័ញ្ច ការរំលោភបំពាន និង ការរត់ពន្ធជនទេសន្តរប្រវេសន៍ និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ។ ព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវការរក្សានូវតុល្យភាពនៃកម្លាំងពលកម្មក្នុងស្រុក ដែលជាសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍរបស់ខ្លួនផងដែរ។ ដើម្បីឆ្លើយតបទៅនឹងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំពង្រឹងការអនុវត្តច្បាប់ និងនីតិវិធីសម្របសម្រួលដល់ការធ្វើទេសន្តរប្រវេសន៍ ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍគ្រប់វិស័យនៅក្នុងប្រទេស ក៏ត្រូវបានយកចិត្តទុកដាក់ដោយពង្រីកការវិនិយោគដើម្បីលើកកម្ពស់វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធ វិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម ជាដើម ដែលអាចបង្កើនការងារ និងមុខរបរជូនប្រជាពលរដ្ឋ រាប់លាននាក់ និងមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ។ ដៃម្ខាងទៀត គឺខិតខំទំនាក់ទំនងពង្រីកឱកាសការងារនៅក្រៅប្រទេសតាមនីតិវិធីស្របច្បាប់ ជាមួយប្រទេសដែលមានសេចក្តីត្រូវការ ។ ក្នុងន័យនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា៖

ទី១. រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងលើក កម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ តាមរយៈខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីធានា បាន
នូវផលប្រយោជន៍ស្របច្បាប់ និងជួយផ្តល់ភាពស្របច្បាប់ដល់ពលករ ។

ទី២. រាជរដ្ឋាភិបាលកំពុងសហការជាមួយប្រទេសជាដៃគូ ទទួលស្គាល់ពលករដែលមានជំនាញ ទៅវិញទៅមកជាមួយកម្ពុជា ។

ទី៣. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ដោយធានាចំពោះពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមាន គ្រោះថ្នាក់ដល់ជីវិត ឲ្យទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ធានារ៉ាប់រង សង្គម គ្រោះថ្នាក់ការងារ និងប្រាក់ធានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។

ទី៤. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធ ន៍និវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាសន្តិសុខ សង្គមពីប្រទេសមួយ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធន និវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។

ទី៥. រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករនៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារ នៅក្នុងប្រទេសឲ្យធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្ត សញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រលប់មកស្រុកកំណើតវិញ។ ដោយឡែកសម្រាប់ ពលករធ្វើការនៅប្រទេសថៃត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាម ច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់។ ទាំងនេះ គឺជាអត្ថប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍ ។

ចំណែកឯពលករក្នុងស្រុក រាជរដ្ឋាភិបាលកម្ពុជា ក៏បាននិងកំពុងលើកកម្ពស់សិទ្ធិ និង អត្ថប្រយោជន៍ស្របច្បាប់ជាច្រើន តាមរយៈការដាក់ចេញ នូវគោលនយោបាយជាបន្តបន្ទាប់ ជាអា ទិ៍ ការតម្លើងបៀវត្សរៀងរាល់ឆ្នាំ ការផ្តល់របបសោធននិវត្តន៍ដល់កម្មករ ការលើកកម្ពស់លក្ខខណ្ឌ ការងារសមស្រប ការផ្តល់ឱកាសឲ្យស្ត្រីមានផ្ទៃពោះ និងស្ត្រីមានទារក បានទទួលនូវអត្ថប្រយោជន៍ បន្ថែមជាដើម ។ មិនតែប៉ុណ្ណោះ ការលើកកម្ពស់ កម្រិតជំនាញបច្ចេកទេសរបស់ពលករ ក៏ត្រូវបាន និងកំពុងតែយកចិត្តទុកដាក់ផងដែរ ។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ លោក លោកស្រី ក្មួយៗ សមាជិក សមាជិកា នៃអង្គពិធីជាទីរាប់អាន

ការរៀបចំពិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាយុទ្ធនាការដ៏ធំមួយ ដែលរាជរដ្ឋាភិបាល មានឱកាសផ្សព្វផ្សាយការយល់ដឹង ឱ្យកាន់តែទូលំទូលាយ និង បានសម្តែងនូវការប្តេជ្ញាចិត្តជូនជនរួមជាតិ និងសហគមន៍អន្តរជាតិអំពីឆន្ទៈដ៏មុះមុត និងកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ក្នុងការគោរពសិទ្ធិមនុស្ស ការការពារសុវត្ថិភាព និងសន្តិសុខប្រជាពលរដ្ឋ ពីការរំលោភបំពានគ្រប់រូបភាព ។ ទោះបីជា អំពើជួញដូរមនុស្ស នៅតែមិនទាន់ស្ងប់ស្ងាត់ និងនៅតែលេចចេញនូវរូបភាពដែលជនល្មើសព្យាយាមបង្កើតឡើង ដើម្បីបំភ័ន្តភ្នែកក្តី ក៏រាជរដ្ឋាភិបាល នៅតែបន្តពង្រឹងការអនុវត្ត និងដាក់ចេញនូវវិធានការ ជាបន្តបន្ទាប់មិនឈប់ឈរឡើយ ។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងវិស័យឯកជនទាំងឡាយ ដែលតែងបានប្រឹងប្រែងរួមគ្នាដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជន ស្របទៅតាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជាការពិតណាស់ ប្រសិនបើមិនមានការប្រឹងប្រែងទេនោះ អំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច រំលោភបំពាន នឹងកាន់តែសកម្ម កាន់តែឃោរឃៅ និងរីករាលដាល និងធ្វើឲ្យស្ថានភាពរឹតតែអាក្រក់ជាងនេះទៅទៀត ។ រីឯប្រជាពលរដ្ឋកាន់តែច្រើននឹងជួបគ្រោះមហន្តរាយ ហើយ សង្គមជាតិ នឹងមិនមានសេចក្តីសុខ និងស្ថេរភាពបានឡើយ ។ យើងមិនត្រូវអនុញ្ញាតឲ្យជនល្មើស ធ្វើសកម្មភាពតាមអំពើចិត្តឡើយ ហើយត្រូវតែអនុវត្តនីតិវិធីផ្តន្ទាទោសតាមច្បាប់ដែលបានកំណត់ ឲ្យបានត្រឹមត្រូវ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមអំពាវនាវ ដល់បណ្តាប្រទេសពាក់ព័ន្ធទាំងអស់ ដែលបានចុះហត្ថលេខារួមគ្នាលើអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គប្បីជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ និងរួមគ្នាពិនិត្យលើចំណុចខ្វះខាតនៃការអនុវត្ត ហើយរួមគ្នាកែលម្អឲ្យបានទាន់ពេលវេលា ។ ជាពិសេសប្រទេស ដែលទទួលពលករកម្ពុជា សូមរក្សាការសន្យាក្នុងកិច្ចព្រមព្រៀង ដែលគូសបញ្ជាក់អំពីការទទួលយកពលករស្របច្បាប់ពីកម្ពុជា និងសូមមេត្តាជួយថែទាំពលករទាំងនោះ ដូចពលរដ្ឋរបស់ខ្លួន ព្រមទាំងជួយការពារពីការរំលោភបំពាន កេងប្រវ័ញ្ច ដែលអាចកើតមានជាយថាហេតុ ។ ក្នុងករណីដែលពលករកម្ពុជាបានប្រព្រឹត្តខុសឆ្គង សូមមេត្តាផ្តល់ព័ត៌មានមករាជរដ្ឋាភិបាលកម្ពុជា ជួយអប់រំ ឬបញ្ជូនត្រឡប់មកកម្ពុជាវិញ តាមផ្លូវច្បាប់ ។

ជាថ្មីម្តងទៀត ខ្ញុំសូមរំលឹក ដាស់តឿនចំពោះមន្ត្រីរាជរដ្ឋាភិបាលទាំងឡាយ ដែលបាន និងកំពុងតែសាងបញ្ហា ឃុបឃិត និងសហការជាមួយជនល្មើសជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំង

ឡាយ ទោះបីដោយចេតនាក្តី អចេតនាក្តី ត្រូវឆាប់ដកខ្លួនជាបន្ទាន់ និងកែខ្លួនឲ្យបានល្អ ព្រោះមិនអាចសម្ងំលាក់លៀមសកម្មភាពទាំងនេះបានទៀតឡើយ ហើយនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់ ។

ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសជាឱឡារិកក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧នេះ ចំពោះមុខសហគមន៍ជាតិ និងអន្តរជាតិ នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបន្តខិតខំប្រឹងប្រែង ដើម្បីឲ្យប្រជាជនកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា ដោយរួមសហការជាមួយបណ្តាដៃគូពាក់ព័ន្ធនានាក្នុងតំបន់ និងលើពិភពលោក ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្ស គ្រប់រូបភាព និងផ្តន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ដើម្បីកាត់បន្ថយ និងលុបបំបាត់ប្រសិទ្ធភាពបទល្មើស ។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមលើកទឹកចិត្ត ឲ្យគ្រប់សមាសភាពក្នុងរាជរដ្ឋាភិបាល ដៃគូអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន បន្តរួមដៃគ្នា អនុវត្តសកម្មភាពព្រមៗគ្នា ពង្រឹងប្រព័ន្ធសុវត្ថិភាព ពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបពីអំពើជួញដូរមនុស្ស ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមប្រគេនពរសព្វសាធុកាចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមឧទ្ទិសបួងសួងដល់គុណព្រះរតនៈត្រ័យ បារមី វត្ថុស័ក្តិសិទ្ធិ សូមប្រទានពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ជូនឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ លោក លោកស្រី នាងកញ្ញា ក្មួយៗ បងប្អូនជនរួមជាតិ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ**

**សូមអរគុណ**



(36)

"Banner for Forum"




១២ធ្នូ ឆ្នាំ ២០១៧


ទិវា ១២ធ្នូ លើកទី ១១
ឆ្នាំ ២០១៧
រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
www.ncct.gov.kh

គំរូអាវយឺត 2017


១២ធ្នូ ឆ្នាំ ២០១៧
ឆ្នាំ ២០១៧
រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
www.ncct.gov.kh

# រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

www.ncct.gov.kh

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គ.ជ.ប.ជ

NATIONAL COMMITTEE FOR COUNTER TRAFFICKING (N.C.C.T)

# ១២ខែ ឆ្នាំ ២០១៧


W.C
A3
D2
E3

| សាលមហោស្រពកោះពេជ្រ | | ចំនួនកៅអី ២៩៧០ | | | 3359 | | -389 | | |
|---|---|---|---|---|---|---|---|---|---|
| | | | | សម្ដេចក្រឡាហោម និងលោកជំទាវ | | | | | |
| E1: 211 | | D1: 182 | | A1: 336 | | B1:182 | | C1: 211 | |
| រាជបណ្ឌិតសភា កម្ពុជា | 5 | គ.ជ.ប.ជ | 27 | ឧប និងទេសរដ្ឋមន្ត្រី | 11 | អង្គទូតបរទេស | 34 | ព្រះសង្ឃ | 50 |
| សាលាភូមិន្ទរដ្ឋបាល | 50 | ក្រុមការងារទាំង៦ | 89 | រដ្ឋសភា និងព្រឹទ្ធសភា | 40 | សមាគមអ្នកសាងសង់ | 21 | យាយជី តាជី | 50 |
| ក្លឹបអ្នកកាសែត | 21 | អភិបាល/រង រាជធានី | 3 | រដ្ឋមន្ត្រី | 18 | សហព័ន្ធស្រូវអង្ករ | 21 | សាសនាកាតូលិក | 50 |
| ប្រធានក្រុម BTV | 1 | ក្រុមប្រឹក្សារាជធានី | 6 | ឯ. កែវ រ៉េមី សិទ្ធមនុស្ស | 1 | អង្គការជាតិ អន្តរជាតិ | 43 | សាសនាគ្រិស្ទ | 50 |
| ប្រធានក្រុម PNN | 1 | អភិបាលខេត្ត | 24 | លោកជំទាវឆាយ វណ្ណនឿន | 1 | CWPD | 8 | ក្រុមហ៊ុនពលករ | 11 |
| សហភាពសម្ព័ន្ធយុវជន | 50 | អភិបាលរងខេត្ត | 24 | រដ្ឋលេខាធិការ | 44 | តំណាងជនជាតិ | 50 | | |
| សមាគមកាត់ដេរ | | ក្រុមប្រឹក្សាខណ្ឌ | 12 | ក្រុមហ៊ុនប៉េងហួត | 1 | | | | |
| សហព័ន្ធសហជីព | | អភិបាលខណ្ឌ | 12 | ក្រុមហ៊ុនពិភពថ្មី | 1 | | | | |
| សាកលវិទ្យាល័យនីតិសាស្ត្រ | 21 | | | អនុរដ្ឋ មហាផ្ទៃ | 33 | | | | |
| | 20 | | | ថ្នាក់អគ្គ មហាផ្ទៃ | 13 | | | | |
| | 54 | | | ថ្នាក់អគ្គរង មហាផ្ទៃ | 19 | | | | |
| | | | | អនុរដ្ឋលេខា ក្រសួងសេដ្ឋកិច្ច | 1 | | | | |
| | | | | សហគ្រិននារី | 21 | | | | |
| | | | | ប្រធាននាយកដ្ឋានមហាផ្ទៃ | 129 | | | | |
| | 223 | | 197 | | 333 | | 177 | | 200 |
| | -12 | | -15 | | 3 | | 5 | | 11 |
| E2: 209 | | D2: 143 | | A2: 264 | | B2:143 | | C2: 209 | |
| ទាហានជើងគោក | 100 | ជើងទឹក | 100 | មេបញ្ជាការ ឬរង PM | 25 | ស្នងការ/រង | 50 | ចៅ/សង្កាត់រង | 105 |
| សាកលភ្នំពេញ | 54 | វិទ្យាស្ថានអប់រំជាតិ | 54 | កងកម្លាំងPM | 100 | កម្លាំងនគរបាល | 100 | ប្រជាជន | 100 |
| សាកលកសិកម្ម | 54 | | | ជើងអាកាស | 100 | | | | |
| | | | | បណ្ឌិត្យសភានគរបាល | 55 | | | | |
| | 208 | | 154 | | 280 | | 150 | | 205 |
| | 1 | | -11 | | -16 | | -7 | | 4 |
| E3: 190 | | D3: 130 | | A3: 240 | | B3:130 | | C3: 190 | |
| កាយរិទ្ធកម្ពុជា | 100 | និ.សាលាភូមិន្ទរដ្ឋបាល | | សាកលវិទ្យាល័យ | 378 | ប្រជាជន | 110 | ប្រជាជន | 190 |
| យុវជនកាកបាទក្រហម | 100 | វិទ្យាស្ថាន វ៉ាន់ដាគណនេយ្យ | 54 | សាកល. ជាតិគ្រប់គ្រង | | សិស្ស វិទ្យាល័យ | 30 | សិស្ស វិទ្យាល័យ | 270 |
| | | | | សាកល. បញ្ញាសាស្ត្រ | | កម្លាំងរក្សាសន្តិសុខ UN | | វិទ្យាល័យ.ស៊ីសុវត្ថិ | |
| | | | | សាកល. នរ័តុន | | សហជីពកម្មករ | | វិទ្យាល័យ.បាក់ទូក | |
| | | | | សាកល. បៀលប្រាយ | | | | វិទ្យាល័យ.បឹងត្របែក | |
| | | | | សាកល. ធនធានមនុស្ស | | | | វិទ្យាល័យ.វត្តកោះ | |
| | | | | សាកល. បៃលធីអន្តរជាតិ | | | | វិទ្យាល័យ.ទួលទំពូង | |
| | | | | សាកល. កម្ពុជា | | | | | |
| | | | | សាកល. បញ្ញាជាតិ | | | | | |
| | 200 | | 54 | | 378 | | 140 | | 460 |
| | -10 | | 76 | | -138 | | -10 | | -270 |

# សម្តេចក្រឡាហោម និងលោកជំទាវ

ចំនួនកៅអី៖ 2.970

| | | | | |
|---|---|---|---|---|
| E1: 211 | D1: 182 | A1: 336 | B1: 182 | C1: 211 |
| E2: 209 | D2: 143 | A2: 264 | B2: 143 | C2: 209 |
| E3: 190 | D3: 130 | A3: 240 | B3: 130 | C3: 190 |

(777)

**សូមគោរពជូន**

សម្តេចពិជ័យសេនា ទៀ បាញ់

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សូមជម្រាបជូន**

ឯកឧត្តម នាយឧត្តមសេនីយ៍ សេង ផល្លី

ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

**សូមគោរពជូន**

ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ

និងជានាយកសាលាភូមិន្ទរដ្ឋបាល

**សូមជម្រាបជូន**

លោកជំទាវឧកញ៉ា អ៊ឹង ស៊ាងរិទ្ធី

ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា

**សូមជម្រាបជូន**

ឯកឧត្តម ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា

**គោរពជូន**

ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

**សូមគោរពជូន**

ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**គោរពជូន**

លោកឧកញ៉ា Charle Vann នាយកប្រតិបត្តិធនាគារកាណាឌីយ៉ា

**សូមជម្រាបជូន**

ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន

អគ្គស្នងការនគរបាលជាតិ និងជាអនុប្រធាន គ.ជ.ប.ជ

"Cover Letter"

**សូមគោរពជូន**
សម្តេចពិជ័យសេនា ទៀ បាញ់
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សូមជម្រាបជូន**
ឯកឧត្តម នាយឧត្តមសេនីយ៍ សេង ផល្លី
ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

**សូមគោរពជូន**
ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ
និងជានាយកសាលាភូមិន្ទរដ្ឋបាល

**សូមជម្រាបជូន**
លោកជំទាវឧកញ៉ា អ៊ឹង ស៊ាងរិទ្ធី
ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា

**សូមជម្រាបជូន**
ឯកឧត្តម ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា

**គោរពជូន**
ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច
ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

**សូមគោរពជូន**
ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**គោរពជូន**
លោកឧកញ៉ា Charle Vann នាយកប្រតិបត្តិធនាគារកាណាឌីយ៉ា

**សូមជម្រាបជូន**
ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន
អគ្គស្នងការនគរបាលជាតិ និងជាអនុប្រធាន គ.ជ.ប.ជ

# សមាសភាពភ្ញៀវចូលរួមទិវាជាតិ ១២ ធ្នូ ឆ្នាំ២០១៧

| ល.រ | សមាសភាព | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | ប្រធាន ឬ អនុប្រធានព្រឹទ្ធសភា គណៈកម្មការទាំង១០ | ២០ | |
| ២ | ប្រធាន ឬ អនុប្រធានសភា គណៈកម្មការទាំង១០ | ២០ | |
| ៣ | អនុប្រធាន និងសមាជិក គ.ជ.ប.ជ | ២៧ | |
| ៤ | ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង | ២៩ | |
| ៥ | រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៤៥ | |
| ៦ | ក្រុមការងារទាំង៦ | ៨៩ | |
| ៧ | អគ្គនាយក និងអគ្គនាយករង ប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ | ១៦១ | |
| ៨ | អភិបាល និងអភិបាលរងរាជធានី ខេត្តទទួលបន្ទុក | ៥០ | |
| ៩ | ស្នងការ និងស្នងការរងរាជធានី ខេត្តទទួលផែន | ៥០ | |
| ១០ | មេបញ្ជាការPM រាជធានី ខេត្ត | ២៥ | |
| ១១ | ថ្នាក់ដឹកនាំ៥ និងនិស្សិតនគរបាល៥០(បណ្ឌិតសភា ន.ប) | ៥៥ | |
| ១២ | ថ្នាក់ដឹកនាំរាជបណ្ឌិតសភាកម្ពុជា | ៥ | |
| ១៣ | សមាជិកក្រុមប្រឹក្សារាជធានី | ៦ | |
| ១៤ | ក្រុមប្រឹក្សាខណ្ឌ១២ | ១២ | |
| ១៥ | អភិបាលខណ្ឌទាំង១២ | ១២ | |
| ១៦ | ចៅសង្កាត់ទាំង១០៥ | ១០៥ | |
| ១៧ | ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ | ៤០០ | |
| ១៨ | ព្រះសង្ឃ | ៥០ | |
| ១៩ | យាយជី តាជី | ៥០ | |
| ២០ | តំណាងសាសនាកាតូលិក | ៥០ | |
| ២១ | តំណាងសាសនាគ្រីស្ទ | ៥០ | |
| ២២ | ខ្មែរឥស្លាម | ៥០ | |
| ២៣ | ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងនិស្សិតគ្រឹះស្ថានរដ្ឋ និងឯកជន | ៧១០ | |
| ២៤ | នាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស វិទ្យាល័យ | ៣០០ | |
| ២៥ | យុវជនកាកបាទក្រហមកម្ពុជា | ១០០ | |
| ២៦ | យុវជនកាយរិទ្ធ | ១០០ | |
| ២៧ | កម្លាំងនគរបាល ចំណុះអគ្គស្នងការនគរបាលជាតិ៖<br>-ឯកសណ្ឋានសាហាវីយ៉េន<br>-ឯកសណ្ឋានប្រយុទ្ធ | <br>៥០<br>៥០ | |
| ២៨ | កងរាជអាវុធហត្ថ | ១០០ | |
| ២៩ | ទាហានជើងគោក | ១០០ | |

| | | | |
|---|---|---|---|
| ៣០ | ទាហានជើងទឹក | ១០០ | |
| ៣១ | ទាហានជើងអាកាស | ១០០ | |
| ៣២ | សាលាភូមិន្ទរដ្ឋបាល | ៥០ | |
| ៣៣ | សហភាពសហព័ន្ធយុវជនកម្ពុជា | ៥០ | |
| ៣៤ | លោកជំទាវ ឧកញ៉ា អ៊ឹង ស៊ាងវិទ្ធី ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា និងសមាជិក | ១១ | |
| ៣៥ | តំណាងសណ្ឋាគារ និងក្លឹបកំសាន្ត | ២០ | |
| ៣៦ | ស្ថាប័នគ្រឹះស្ថានហិរញ្ញវត្ថុ | ២០ | |
| ៣៧ | តំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា | ២៨ | |
| ៣៨ | អង្គការដៃគូ (លោកទិត្យ សម្របសម្រួល) | ៥០ | |
| ៣៩ | អ្នកឧកញ៉ា **ពុង ឃាវសែ** ប្រធានសមាគមអ្នកសាងសង់កម្ពុជា (CCA)និងសមាជិក | ២១ | |
| ៤០ | ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិក | ២១ | |
| ៤១ | សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) / ឯ.ឧ **សោម អូន** ប្រធានសភាសហព័ន្ធសហជីពជាតិកម្ពុជា (NACC) | ២០ | ១ |
| ៤២ | សហជីពកម្មករ | ២០ | |
| ៤៣ | លោក **ប៉ែន បូណា** ប្រធានក្លឹបអ្នកកាសែតកម្ពុជា និងសមាជិក | ២១ | |
| ៤៤ | លោកស្រី **ចន ច័ន្ទលក្ខិណា** ប្រធានសមាគមអ្នកសិល្បៈកម្ពុជា និងសមាជិក | ២១ | |
| ៤៥ | ឧកញ៉ា **កែវ មុំ** ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា និងសមាជិក | ២១ | |
| ៤៦ | ឯកឧត្តម **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ១ | |
| ៤៧ | លោកជំទាវ **ឆាយ វ៉ាន់នឿន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១ | |
| ៤៨ | លោកជំទាវ **កែវ ចរិយា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | |
| ៤៩ | លោកជំទាវ **តាន់ ផល្លី** សមាគមស្ត្រីសហគ្រិន | ១ | |
| ៥០ | លោក **សៅ ភិរុណ** ប្រធានក្រុមការងារផលិតបទយកការណ៍ BTV | ១ | |
| ៥១ | ឧកញ៉ា **ថៃ ជាហ៊្វិត** ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនប៉េង ហួត គ្រុប | ១ | |
| ៥២ | អ្នកឧកញ៉ា **ហុង ពីវ** ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនពិភពថ្មី | ១ | |
| | សរុប | ៣.៤៥៣នាក់ | |

(49)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សមាសភាពដែលត្រូវអញ្ជើញចូលរួមទិវាជាតិ ១២ ធ្នូ ឆ្នាំ២០១៧
# នៅសាលមហោស្រពកោះពេជ្រ

| ល.រ | គ្រឹះស្ថានឧត្តមសិក្សា/សាលាវិទ្យាល័យ | សម្លៀកបំពាក់ | អ្នកចូលរួម | | | សរុប |
|---|---|---|---|---|---|---|
| | | | ថ្នាក់ដឹកនាំ | សាស្ត្រាចារ្យ | សិស្ស/និស្សិត | |
| ១ | វិទ្យាស្ថានជាតិអប់រំ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ២ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៣ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៤ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៥ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៦ | សាកលវិទ្យាល័យបញ្ញាសាស្ត្រ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៧ | សាកលវិទ្យាល័យន័រតុន | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៨ | សាកលវិទ្យាល័យបៀលប្រាយ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ៩ | សាកលវិទ្យាល័យធនធានមនុស្ស | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ១០ | សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ១១ | សាកលវិទ្យាល័យកម្ពុជា | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ១២ | សាកលវិទ្យាល័យបញ្ញាជាតិ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ១៣ | វិទ្យាស្ថានវ៉ាន់ដាគណនេយ្យ | អាវយឺតទិវា | ២ | ២ | ៥០ | ៥៤ |
| ១៤ | វិទ្យាល័យព្រះស៊ីសុវត្ថិ | អាវយឺតទិវា | ២ | ៣ | ៥៥ | ៦០ |
| ១៥ | វិទ្យាល័យបាក់ទូក | អាវយឺតទិវា | ២ | ៣ | ៥៥ | ៦០ |
| ១៦ | វិទ្យាល័យបឹងត្របែក | អាវយឺតទិវា | ២ | ៣ | ៥៥ | ៦០ |
| ១៧ | វិទ្យាល័យវត្តកោះ | អាវយឺតទិវា | ២ | ៣ | ៥៥ | ៦០ |
| ១៨ | វិទ្យាល័យទួលទំពូង | អាវយឺតទិវា | ២ | ៣ | ៥៥ | ៦០ |
| ១៩ | យុវជនកាកបាទក្រហមកម្ពុជា | ឯកសណ្ឋាន | ១ | ៣ | ១០០ | ១០៤ |
| ២០ | យុវជនកាយរិទ្ធកម្ពុជា | ឯកសណ្ឋាន | ១ | ៣ | ១០០ | ១០៤ |
| សរុបរួម | | | ១២១០នាក់ | | | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

ជ.ប្រធាន គ.ជ.ប.ជ

អនុប្រធានអចិន្ត្រៃយ៍

(50)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# បញ្ជីឈ្មោះតំណាងស្ថានទូតដែលត្រូវអញ្ជើញចូលរួមទិវាជាតិ ១២ ធ្នូ ឆ្នាំ២០១៧
## នៅសាលមហោស្រពកោះពេជ្រ

| ល.រ | ប្រទេស | សម្លៀកបំពាក់ | ផ្សេងៗ |
|---|---|---|---|
| 1 | Australia | អាវយឺតទិវា | |
| 2 | Bulgaria | អាវយឺតទិវា | |
| 3 | Brunei | អាវយឺតទិវា | |
| 4 | Cuba | អាវយឺតទិវា | |
| 5 | Czech | អាវយឺតទិវា | |
| 6 | China | អាវយឺតទិវា | |
| 7 | EU | អាវយឺតទិវា | |
| 8 | France | អាវយឺតទិវា | |
| 9 | Germany | អាវយឺតទិវា | |
| 10 | Indonesia | អាវយឺតទិវា | |
| 11 | India | អាវយឺតទិវា | |
| 12 | Japan | អាវយឺតទិវា | |
| 13 | Kuwait | អាវយឺតទិវា | |
| 14 | Lao PDR | អាវយឺតទិវា | |
| 15 | Malaysia | អាវយឺតទិវា | |
| 16 | Myanmar | អាវយឺតទិវា | |
| 17 | North Korea | អាវយឺតទិវា | |
| 18 | Pakistan | អាវយឺតទិវា | |
| 19 | Philippines | អាវយឺតទិវា | |
| 20 | Republic of Korea | អាវយឺតទិវា | |
| 21 | Russia | អាវយឺតទិវា | |
| 22 | Sweden | អាវយឺតទិវា | |
| 23 | Singapore | អាវយឺតទិវា | |
| 24 | Turkey | អាវយឺតទិវា | |
| 25 | Thailand | អាវយឺតទិវា | |
| 26 | United State of America | អាវយឺតទិវា | |
| 27 | United Kingdom | អាវយឺតទិវា | |
| 28 | Viet Nam | អាវយឺតទិវា | |
| សរុប | | 28 ប្រទេស | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**ជ.ប្រធាន គ.ជ.ប.ជ**

**អនុប្រធានអចិន្ត្រៃយ៍**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
**អគ្គលេខាធិការដ្ឋាន**

**បញ្ជីវត្តមាន**

រៀបចំកិច្ចប្រជុំទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ ២០១៧ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៧ នៅសាលសន្និបាតកោះពេជ្រ

| ល.រ | នាម-គោតនាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| No. | Name | sex | Position | organization | Telephone | signature |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

(52)

| ល.រ | នាម-គោត្តនាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| No. | Name | sex | Position | organization | Telephone | signature |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| ល.រ | នាម-គោតនាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| No. | Name | sex | Position | organization | Telephone | signature |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| ល.រ | នាម-គោតនាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| No. | Name | sex | Position | organization | Telephone | signature |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប
លេខៈ ១៦១/១៧ ល.ម.ន.

**គោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

**កម្មវត្ថុ:** របាយការណ៍ស្តីពី ការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ២០១៧ ។
**យោង:** លិខិត ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៧៤៨សជណ.អវ. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ លេខាធិការដ្ឋានរដ្ឋបាលសរុប មានកិត្តិយសសូមគោរពជម្រាបជូន លោកជំទាវ មេត្តាជ្រាបថា អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ នាថ្ងៃអង្គារ ទី៩រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ គ.ស ២០១៧ នៅសាលមហោស្រពកោះពេជ្រដូចខាងក្រោម៖

**ក.អំពីសមាសភាព**

- សមាជិក សមាជិកាព្រឹទ្ធសភា និងរដ្ឋសភា
- សមាជិក សមាជិការាជរដ្ឋាភិបាល
- អគ្គនាយក អគ្គនាយករង ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- អគ្គលេខាធិការ អគ្គលេខាធិការរង ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- តំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា
- អភិបាល អភិបាលរងរាជធានី ខេត្ត
- ក្រុមប្រឹក្សារាជធានី ខណ្ឌ និងចៅសង្កាត់
- កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- សហភាពសហព័ន្ធយុវជនកម្ពុជា
- អង្គការដៃគូជាតិ និងអន្តរជាតិ
- វិស័យឯកជន និងសមាគម
- ព្រះសង្ឃ តាជី យាយជី និងប្រជាពលរដ្ឋ ខ្មែរឥស្លាម
- តំណាងសាសនានានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស យុវជនកាយរិទ្ធ និងកាកបាទក្រហម

សរុបចំនួន៖ ៣,២៣២ អង្គ/នាក់

**ខ.អំពីកម្មវិធី**

- ការអញ្ជើញមកដល់ និងការបង្ហោះប៉េងប៉ោងដោយ សម្តេចក្រឡាហោម និងគណៈអធិបតីដែលបានចូលរួម

- ប្រកាសហេតុ និងគោលបំណង នៃដំណើរការកម្មវិធី
- មតិស្វាគមន៍ និងរបាយការណ៍សង្ខេបដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
- ការបង្ហាញខ្សែវីដេអូខ្លីស្តីពីបទយកការណ៍អំពីស្ថានភាព នៃអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាល នឹងប្រជាជនកម្ពុជា និងការសម្តែងសិល្បៈរបាំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- សុន្ទរកថា និងមតិដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូមលោកជំទាវមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ គ.ស២០១
**អ្នកធ្វើរបាយការណ៍**
ស៊ុ.ឆារិទ្ធ

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៤ខែ ធ្នូ គ.ស២០១៧
**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

**ឧត្តមសេនីយ៍ទោ. គង់ ពុទ្ធី**

បានឃើញ
ត្រៀមប្រមូលឧបករណ៍ គ្រប់ឯកសារ
និងសម្ភារៈក្នុងពិធីនោះ
កម្មវិធី តាមគន្លង ខុទ្ទកាល័យ ឯកសារការិយាល័យ

14/12/17

ជូ ប៊ុនអេង



(57)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខៈ ១៦១/១៧ ......

# គោរពជូន

# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

**កម្មវត្ថុ:** របាយការណ៍សង្ខេប ស្តីពីការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ២០១៧ ។

**យោង:** លិខិត ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៧៤៨សជណ.អវ. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៧ ។

ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានរៀបចំប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីនេះ មានឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា ដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិ ផ្នែកឯកជន ផ្នែកសាសនា សកលវិទ្យាល័យរាជបណ្ឌិត្យសភាកម្ពុជា សាលាបណ្ឌិត្យសភានគរបាលកម្ពុជា សាលាបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ យុវជន សិស្ស និស្សិត សហភាពសហព័ន្ធយុវជន សមាគមនារី យុវជនកាយរិទ្ធ យុវជនកាកបាទក្រហម កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីពីគ្រប់រាជធានី ខេត្ត និងបងប្អូនប្រជាពលរដ្ឋយ៉ាងច្រើនកុះករសរុបប្រមាណជាង ៣,២៣២នាក់ ផងដែរ។

នៅក្នុងទិវាដ៏ឧត្តុង្គឧត្តមនេះ **សម្តេចក្រឡាហោម** បានបញ្ជាក់ អំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជាជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាល បានចាត់ទុកអំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋ និងប្តេជ្ញាចិត្តទប់ស្កាត់ និង បង្ក្រាបបទល្មើសនេះឲ្យបានខ្លាំងក្លា ដោយមិនអនុញ្ញាតឲ្យជនល្មើសមានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ ។ បទល្មើសជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មឆ្លងដែន ដែលកាន់តែស្រួចស្រាល និងគ្រោះថ្នាក់ជាទីបំផុតដល់មនុស្សជាតិ ជាពិសេស ក្នុងចំណោមពលករទេសន្តរប្រវេសន៍ ដែលបានចាកចេញទៅធ្វើការងារនៅក្រៅប្រទេស និងជនភៀសខ្លួន ទាំងក្មេង ចាស់ ប្រុសស្រី ដោយមិនរើសមុខ ។ គណៈកម្មាធិការជាតិ បានសំរេចការអនុវត្តយុទ្ធសាស្ត្រទាំងបួន គឺ ការងារបង្ការទប់ស្កាត់ ការការពារជនរងគ្រោះ ការអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហការ ក្នុងការរៀបចំ និងជំរុញការរៀបចំច្បាប់ គោលនយោបាយនានាឱ្យកាន់តែមានប្រសិទ្ធិភាព ។ ក្នុងពេលកន្លងទៅព្រះរាជាណាចក្រកម្ពុជា បានដោះស្រាយបញ្ហាទាំងនេះយ៉ាងយកចិត្តទុកដាក់ ដើម្បីរក្សានូវតុល្យភាពនៃតម្រូវការ និងការផ្គត់ផ្គង់ ព្រមទាំងពង្រឹងសន្តិសុខដល់ប្រជាពលរដ្ឋ និង



(58)

ភៀសខ្លួនទាំងឡាយ ឲ្យស្នាក់នៅក្នុងកម្ពុជាប្រកបដោយភាពកក់ក្ដៅ មានសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្ត ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ការលំបាក និងភាពប្រឈមនៃប្រទេសទាំងសងខាង គឺប្រទេសបញ្ជូន និងប្រទេសទទួលក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ និងបទល្មើសទាំងឡាយដែលកើតឡើងក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ និងនៅក្នុងប្រទេសគោលដៅ ។

សម្ដេចក្រឡាហោម បានបញ្ជាក់ថាៈ ប្រទេសដែលមានការពាក់ព័ន្ធ ចាំបាច់ត្រូវឯកភាពគ្នា ដើម្បីអនុវត្តបែបបទនីតិវិធី ដែលបានព្រមព្រៀងគ្នាក្នុងអនុស្សរណៈ។ ក្នុងនាមជាប្រទេសបញ្ជូន រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវបទដ្ឋានគតិយុត្តិជាច្រើន ដែលក្នុងនោះរួមទាំងការអនុញ្ញាតឲ្យមានក្រុមហ៊ុនជាច្រើនទទួលបានអាជ្ញាប័ណ្ណដើម្បីធ្វើការជ្រើសរើស បណ្ដុះបណ្ដាល និងបញ្ជូនដោយស្របច្បាប់ ។ តែទន្ទឹមនឹងនោះ ការអនុវត្តនៅតែមានភាពខ្វះចន្លោះទាំងសងខាង ដែលនាំឲ្យបញ្ហាកាន់តែស្មុគស្មាញ ។ ព្រះរាជាណាចក្រកម្ពុជា គាំទ្រការធ្វើទេសន្តរប្រវេសន៍ ដែលមានសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដើម្បីបញ្ចៀសហានិភ័យរបស់ពលករ ពីការកេងប្រវ័ញ្ច ការរំលោភបំពាន និង ការរត់ពន្ធជនទេសន្តរប្រវេសន៍ និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ។ ព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវការរក្សានូវតុល្យភាពនៃកម្លាំងពលកម្មក្នុងស្រុក ដែលជាសេចក្ដីត្រូវការសម្រាប់ការអភិវឌ្ឍរបស់ខ្លួនផងដែរ។ ដើម្បីឆ្លើយតបទៅនឹងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំពង្រឹងការអនុវត្តច្បាប់ និងនីតិវិធីសម្របសម្រួលដល់ការធ្វើទេសន្តរប្រវេសន៍ ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍគ្រប់វិស័យនៅក្នុងប្រទេសក៏ត្រូវបានយកចិត្តទុកដាក់ដោយពង្រីកការវិនិយោគ ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធ វិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម ជាដើម ដែលអាចបង្កើនការងារ និងមុខរបរជូនប្រជាពលរដ្ឋ រាប់លាននាក់ និងមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ។ ដៃម្ខាងទៀត គឺខិតខំទំនាក់ទំនងពង្រីកឱកាសការងារនៅក្រៅប្រទេសតាមនីតិវិធីស្របច្បាប់ ជាមួយប្រទេសដែលមានសេចក្ដីត្រូវការ ។ ក្នុងន័យនេះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ **ព្រះរាជាណាចក្រកម្ពុជា** បានបញ្ជាក់ថាៈ

**ទី១.** រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ តាមរយៈខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីធានាបាននូវផលប្រយោជន៍ស្របច្បាប់ និងជួយផ្ដល់ភាពស្របច្បាប់ដល់ពលករ ។

**ទី២.** រាជរដ្ឋាភិបាលកំពុងសហការជាមួយប្រទេសជាដៃគូ ទទួលស្គាល់ពលករដែលមានជំនាញទៅវិញទៅមកជាមួយកម្ពុជា ។

**ទី៣.** រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្ដាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គម ដោយធានាចំពោះពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ជីវិត ឲ្យទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ធានារ៉ាប់រងសង្គមគ្រោះថ្នាក់ការងារ និងប្រាក់ធានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។

ទី៤. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធន៍និវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាសន្តិសុខសង្គមពីប្រទេសមួយ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធននិវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។

ទី៥. រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករនៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារនៅក្នុងប្រទេសឲ្យធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រលប់មកស្រុកកំណើតវិញ ។ ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទេសថៃ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់ ។ ទាំងនេះ គឺជាអត្ថប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍ ។

ចំណែកឯពលករក្នុងស្រុក រាជរដ្ឋាភិបាលកម្ពុជា ក៏បាន និងកំពុងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់ជាច្រើន តាមរយៈការដាក់ចេញ នូវគោលនយោបាយជាបន្តបន្ទាប់ជាអាទិ៍ដូចជាការ តម្លើងបៀវត្សរៀងរាល់ឆ្នាំ ការផ្តល់របបសោធននិវត្តន៍ដល់កម្មករ ការលើកកម្ពស់លក្ខខណ្ឌការងារសមស្រប ការផ្តល់ឱកាសឲ្យស្ត្រីមានផ្ទៃពោះ និងស្ត្រីមានទារក បានទទួលនូវអត្ថប្រយោជន៍បន្ថែមជាដើម ។ មិនតែប៉ុណ្ណោះ ការលើកកម្ពស់ កម្រិតជំនាញបច្ចេកទេសរបស់ពលករ ក៏ត្រូវបាន និងកំពុងតែយកចិត្តទុកដាក់ផងដែរ ។

ឆ្លៀតក្នុងឱកាសនេះ សម្តេចក្រឡាហោម បានថ្លែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងវិស័យឯកជនទាំងឡាយ ដែលតែងបានប្រឹងប្រែងរួមគ្នាដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជន ស្របទៅតាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជាការពិតណាស់ ប្រសិនបើមិនមានការប្រឹងប្រែងទេនោះអំពើជួញដូរមនុស្សអំពើកេងប្រវ័ញ្ច រំលោភបំពាន នឹងកាន់តែសកម្ម កាន់តែឃោរឃៅ និងរីករាលដាល និងធ្វើឲ្យស្ថានភាពរឹតតែអាក្រក់ជាងនេះទៅទៀត ។ រីឯប្រជាពលរដ្ឋកាន់តែច្រើននឹងជួបគ្រោះមហន្តរាយ ហើយ សង្គមជាតិ នឹងមិនមានសេចក្តីសុខ និងស្ថេរភាពបានឡើយ ។ យើងមិនត្រូវអនុញ្ញាតឲ្យជនល្មើស ធ្វើសកម្មភាពតាមអំពើចិត្តឡើយ ហើយត្រូវតែអនុវត្តនីតិវិធីផ្តន្ទាទោសតាមច្បាប់ដែលបានកំណត់ ឲ្យបានត្រឹមត្រូវ ។

ក្នុងនាម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសជាឱឡារិកក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧នេះ ចំពោះមុខសហគមន៍ជាតិ និងអន្តរជាតិ នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយៈ បន្តខិតខំប្រឹងប្រែង ដើម្បីឲ្យប្រជាជនកម្ពុជា និងមនុស្ស

ជាតិ ទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា ដោយរួមសហការជាមួយបណ្តាដៃគូពាក់ព័ន្ធនានា ក្នុងតំបន់ និងលើពិភពលោក ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្ស គ្រប់រូបភាព និងផ្តន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ដើម្បីកាត់បន្ថយ និងលុបបំបាត់ប្រសិទ្ធភាពបទល្មើស ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមអំពាវនាវ ដល់បណ្តាប្រទេសពាក់ព័ន្ធទាំងអស់ ដែលបានចុះហត្ថលេខារួមគ្នាលើអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គប្បីជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ និងរួមគ្នាពិនិត្យលើចំណុចខ្វះខាតនៃការអនុវត្ត ហើយរួមគ្នាកែលម្អឲ្យបានទាន់ពេលវេលា ។ ជាពិសេសប្រទេស ដែលទទួលពលករកម្ពុជា សូមរក្សាការសន្យាក្នុងកិច្ចព្រមព្រៀង ដែលគូសបញ្ជាក់អំពីការទទួលយកពលករស្របច្បាប់ពីកម្ពុជា និងសូមមេត្តាជួយថែទាំពលករទាំងនោះ ដូចពលរដ្ឋរបស់ខ្លួន ព្រមទាំងជួយការពារពីការរំលោភបំពានកេងប្រវ័ញ្ច ដែលអាចកើតមានជាយថាហេតុ ។ ក្នុងករណីដែលពលករកម្ពុជាបានប្រព្រឹត្តខុសឆ្គង សូមមេត្តាផ្តល់ព័ត៌មានមករាជរដ្ឋាភិបាលកម្ពុជា ជួយអប់រំ ឬបញ្ជូន ត្រឡប់មកកម្ពុជាវិញ តាមផ្លូវច្បាប់ ។

ការប្រារព្ធទិវាជាតិ១២ធ្នូ ២០១៧ នៅសាលមហោស្រពកោះពេជ្រ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសរីករាយ និងសាមគ្គីភាព ។

សេចក្តីដូចបានគោរព រាយការណ៍ជូនដូចខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ គ.ស២០១៧

**ជ.ប្រធានក្រុមការងាររបាយការណ៍**

hantha

**ប៉ុណ្ណ ចន្ថា**

បានឃើញ

19/12/17

**ជូ ប៊ុនអេង**



(61)